ក្រសួងអប់រំ យុវជន និងកីឡា
Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ
National Institute of Education

# និក្ខេបបទ

# ស្ថានភាពនៃការប្រើប្រាស់វិធីសាស្ត្របង្រៀនភាសាអង់គ្លេស
# នៅមធ្យមសិក្សាបឋមភូមិ
# ករណីសិក្សា៖ រាជធានីភ្នំពេញ

Situation of Using English Teaching Methods in

Lower Secondary School

Case Study: Phnom Penh

ដោយ/by

**អ៊ីវ សុធី**

**IV SOTHY**

ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦

ឯកទេស៖ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា ២០១៧-២០១៩

ឧបត្ថម្ភដោយ៖ មូលនិធិគាំទ្រការអប់រំអន្តរជាតិនៅកម្ពុជា
Supported by Cambodia International Education Support Foundation ( CIESF )

# ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

# វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

# ស្ថានភាពនៃការប្រើប្រាស់វិធីសាស្ត្របង្រៀនភាសាអង់គ្លេស

# នៅមធ្យមសិក្សាបឋមភូមិ

# ករណីសិក្សា៖ រាជធានីភ្នំពេញ

Situation of Using English Teaching Methods in

Lower Secondary School

Case Study: Phnom Penh

**ដោយ**/by

**អ៊ីវ សុធី**

IV SOTHY

**ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦**
**ឯកទេស៖ គ្រប់គ្រងអប់រំ**
**ឆ្នាំសិក្សា ២០១៧-២០១៨**

**សាស្ត្រាចារ្យដឹកនាំ៖ បណ្ឌិត នួវ វីរ៉ា**
**សាស្ត្រាចារ្យដឹកនាំរង៖ ម៉ៅ សារឿន**

**ឧបត្ថម្ភដោយ៖ មូលនិធិគាំទ្រការអប់រំអន្តរជាតិនៅកម្ពុជា**
Supported by Cambodia International Education Support Foundation ( CIESF )

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខ:** ៥៧២៩ **អយក.**[illegible]

(**ការសម្គាល់**)

## លិខិតឧទ្ទេសនាម

**យោង ៖** -បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។

-ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦ និងទី៧ ឆ្នាំសិក្សា២០១៨-២០១៩ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៨។

មន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការការពារនិក្ខេបបទ** សម្រាប់ការការពារនិក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦ ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី១០-១១ ខែធ្នូ ឆ្នាំ២០១៩ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | |
|---|---|---|
| ១-ឯ.ឧ បណ្ឌិត ជ័យ សារិន | អគ្គាធិការដ្ឋាន | ប្រធាន |
| ២-ឯ.ឧបណ្ឌិត សៀង សុវណ្ណា | វិទ្យាស្ថានជាតិអប់រំ | អនុប្រធាន |
| ៣-ឯកឧត្តម លឹម សុធា | អគ្គនាយកដ្ឋានគោលនយោបាយនិងផែនការ | សមាជិក |
| ៤-លោកបណ្ឌិត នូវ រីក | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥-ឯកឧត្តម ងៀ សុផន | នាយកដ្ឋានបុគ្គលិក | សមាជិក |
| ៦-លោកជំទាវបណ្ឌិត យូន រិទ្ធិកា | អគ្គនាយកដ្ឋានអប់រំ | សមាជិក |
| ៧-លោក នី បុណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៨-ឯ.ឧបណ្ឌិត ម៉ុក សារុំម | អគ្គនាយកដ្ឋានអប់រំ | សមាជិក |
| ៩-ឯ.ឧបណ្ឌិត នី ខាំបូលី | អគ្គនាយកដ្ឋានគោលនយោបាយ | សមាជិក |
| ១០-ឯ.ឧ បណ្ឌិត សិន សេងហុក | នាយកដ្ឋាននីតិកម្ម | សមាជិក |
| ១១-លោកបណ្ឌិត សិត សេង | វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ | សមាជិក |
| ១២-លោកបណ្ឌិត ឈួក ច័ន្ទឆាយា | នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ | សមាជិក |
| ១៣-លោកបណ្ឌិត នី វដ្ឋា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

ឯកឧត្តម លោកជំទាវ អស់លោក ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិតនៅថ្ងៃទី១០-១១ ខែធ្នូ ឆ្នាំ២០១៩ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅនៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃ សុក្រ ១ រោច ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែវិច្ឆិកា ឆ្នាំ២០១៩
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**
-អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រីក្រសួងអយក
-គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ
"ដើម្បីជ្រាបជាព័ត៌មាន"
-សាមីខ្លួន "ដើម្បីអនុវត្ត"
-កាលប្បវត្តិ - ឯកសារវិទ្យាស្ថានជាតិអប់រំ

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

# សេចក្តីប្រកាសរបស់បេក្ខជន

ខ្ញុំបាទសូមបញ្ជាក់ថា និក្ខេបបទស្រាវជ្រាវដែលមានចំណងជើងថា "**ស្ថានភាពនៃការប្រើប្រាស់វិធីសាស្ត្របង្រៀនភាសារអង់គ្លេសនៅមធ្យមសិក្សាបឋមភូមិ**" សម្រាប់បំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាន់ទី៦ ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ គឺជាស្នាដៃរបស់ខ្ញុំបាទទាំងស្រុង។ ចំពោះស្នាដៃនេះ ពុំទាន់ត្រូវបានប្រើប្រាស់ដើម្បីបំពេញលក្ខខណ្ឌសិក្សាសម្រាប់ទទួលសញ្ញាបត្រនៅវិទ្យាស្ថាននេះ ឬសាកលវិទ្យាល័យ ឬវិទ្យាស្ថានណាមួយនៅឡើយទេ។ ហើយក៏ពុំមានខ្លឹមសារណាមួយដែលបានប្រើប្រាស់ក្នុងអត្ថបទស្រាវជ្រាវនេះគ្មានការអនុញ្ញាតពីអ្នកនិពន្ធ ឬចុះបញ្ជីឯកសារយោងឡើយ ។ និក្ខេបបទស្រាវជ្រាវខាងលើនេះ គឺជាស្នាដៃរបស់ខ្ញុំបាទតែម្នាក់ឯងពិតប្រាកដដោយពុំមានចាប់ដៃគូជាមួយនិស្សិតណាម្នាក់ឡើយ។

ថ្ងៃអង្គារ ១៤ កើត ខែ មិគសិរ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែធ្នូ ឆ្នាំ ២០១៩

**ហត្ថលេខាបេក្ខជន**

**អ៊ឹម សុធី**

# លិខិតបញ្ជាក់

| | | | |
|---|---|---|---|
| បណ្ឌិត | **នួន** | **វីរ៉ា** | ជាសាស្ត្រាចារ្យដឹកនាំ |
| លោក | **ម៉ៅ** | **សារឿន** | ជាសាស្ត្រាចារ្យដឹកនាំរង |

## សូមបញ្ជាក់ និងទទួលស្គាល់ថា

លោក **អ៊ីវ សុធី** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦ ពិតជាបានសរសេរនិក្ខេបបទស្រាវជ្រាវ "**ស្ថានភាពនៃការប្រើប្រាស់វិធីសាស្ត្របង្រៀនភាសាអង់គ្លេសនៅមធ្យមសិក្សាបឋមភូមិ**" ករណីសិក្សា៖ រាជធានីភ្នំពេញ ពិតប្រាកដមែន។

ថ្ងៃអង្គារ ១៤កើត ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែធ្នូ ឆ្នាំ ២០១៩

..........................................

បណ្ឌិត **នួន វីរ៉ា**

នាយករងវិទ្យាស្ថានជាតិអប់រំ

..................................

លោក **ម៉ៅ សារឿន**

ប្រធានដេប៉ាតឺម៉ង់អប់រំ

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទសូមថ្លែងអំណរគុណចំពោះក្រសួងអប់រំ យុវជន និងកីឡា វិទ្យាស្ថានជាតិអប់រំ និងអង្គការមូលនិធិគាំទ្រការអប់រំអន្តរជាតិកម្ពុជា (Cambodia International Education Support Foundation (CIESF)) របស់ប្រទេសជប៉ុនដែលបានរៀបចំ និងផ្តល់នូវអាហារូបករណ៍ ក៏ដូចជាផ្តល់ឱកាសដល់រូបខ្ញុំបាទ បានសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំនាពេលកន្លងមក។

ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ចំពោះគណៈកម្មការគ្រប់គ្រងការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៃវិទ្យាស្ថានជាតិអប់រំ ព្រមទាំងសាស្ត្រាចារ្យទាំងអស់ ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការបង្ហាត់បង្រៀនដល់រូបខ្ញុំ។

ខ្ញុំបាទសូមថ្លែងអំណរគុណ ចំពោះសាស្ត្រាចារ្យដឹកនាំបង្គោល បណ្ឌិត **នួន វីរ៉ា** ដែលតែងតែចំណាយពេលវេលាដ៏មានតម្លៃដើម្បីពន្យល់ណែនាំ កែលម្អនូវចំណុចខ្វះខាត និងផ្តល់គំនិតយោបល់ល្អៗដល់រូបខ្ញុំបាទគ្រប់ជំហានតាំងពីចាប់ផ្តើមនៃការសរសេរ ទើបធ្វើឱ្យការស្រាវជ្រាវរបស់ខ្ញុំក្នុងពេលនេះ ទទួលបានជោគជ័យ និងបញ្ចប់ដោយរលូន។

ខ្ញុំបាទសូមថ្លែងអំណរគុណផងដែរចំពោះ លោក **ម៉ៅ សារឿន** ជាសាស្ត្រាចារ្យដឹកនាំរងដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការជួយបង្ហាត់បង្ហាញផ្លូវ និងផ្តល់យោបល់ជាគន្លឹះសំខាន់ៗ ដល់រូបខ្ញុំបាទក្នុងការស្រាវជ្រាវនេះ ចាប់តាំងពីដើមរហូតទទួលបានជោគជ័យត្រចះត្រចង់នេះ។

ខ្ញុំបាទសូមថ្លែងអំណរគុណលោកនាយក/នាយិកា លោកយករង/នាយិការង លោកគ្រូ អ្នកគ្រូបង្រៀនភាសាអង់គ្លេសពីថ្នាក់ទី៧ដល់ទី៩ (នៅតាមសាលាគោលដៅ) ដែលបានចូលរួមសហការណ៍ក្នុងដំណើរការប្រមូលទិន្នន័យធ្វើឱ្យការសិក្សាស្រាវជ្រាវនេះទទួលបានជោគជ័យ។

ជាទីបញ្ចប់ ខ្ញុំបាទសូមសម្បូងសម្រូងដល់វត្ថុស័ក្តសិទ្ធិក្នុងលោកតាមជួយថែរក្សា ឯកឧត្តមលោកជំទាវ លោកសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ សិស្សានុសិស្សទាំងអស់ សូមមានសុខភាពល្អបរិបូណ៌ កម្លាំងពលំមាំមួន និងជួបប្រទះនូវ ពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

**សូមអរគុណ**!

# មូលន័យសង្ខេប

ការអប់រំត្រូវបានទទួលស្គាល់ជាសកលថា ជាសិទ្ធិមនុស្សជាមូលដ្ឋានដើម្បីទទួលបាននូវចំណេះដឹង ជំនាញ និងឥរិយាបថថ្លៃថ្នូរសម្រាប់ការអភិវឌ្ឍសង្គមនាពេលបច្ចុប្បន្ន ដែលក្រសួងអប់រំ យុវជន និងកីឡា បានចាប់ផ្តើមធ្វើកំណែទម្រង់ប្រព័ន្ធអប់រំចាប់តាំងពីដើមអាណត្តិទី៥នៃរដ្ឋសភាមក ដោយបានលើកឡើងនូវយុទ្ធសាស្ត្រគន្លឹះ ០៨ចំណុច ក្នុងដំណើរការកំណែទម្រង់នោះ។

ការសិក្សាស្រាវជ្រាវស្តីពី "ស្ថានភាពនៃការប្រើប្រាស់វិធីសាស្ត្របង្រៀនភាសាអង់គ្លេសនៅមធ្យមសិក្សាបឋមភូមិ" ត្រូវបានរៀបចំឡើងក្នុងគោលបំណងស្វែងរកឱ្យឃើញពីប្រសិទ្ធភាពនិងភាពញឹកញាប់នៃការប្រើប្រាស់វិធីសាស្ត្របង្រៀនភាសាអង់គ្លេសនៅមធ្យមសិក្សាបឋមភូមិ ដែលលោកគ្រូ អ្នកគ្រូជ្រើសរើសយកមកប្រើនៅក្នុងការបង្រៀន។

ការសិក្សាស្រាវជ្រាវប្រធានបទនេះ ផ្អែកទៅលើទ្រឹស្តី និងឯកសាររបស់ស្ថាប័នពាក់ព័ន្ធផ្នែកអប់រំមួយចំនួនទាំងនៅក្នុងប្រទេស និងអន្តរជាតិ។ ការសិក្សាស្រាវជ្រាវនេះ ត្រូវបានអនុវត្តតែនៅមធ្យមសិក្សាបឋមភូមិ នៅក្នុងរាជធានីភ្នំពេញប៉ុណ្ណោះ។ នៅទីនោះសិស្សានុសិស្សដែលកំពុងសិក្សាថ្នាក់ទី៧ ថ្នាក់ទី៨ និងថ្នាក់ទី៩ ជាមួយនឹងលោកគ្រូ អ្នកគ្រូដែលកំពុងបង្រៀនមុខវិជ្ជាភាសាអង់គ្លេសមួយចំនួន គឺជាគោលដៅដែលត្រូវជ្រើសរើសដើម្បីបំពេញកម្រងសំណួរ និងសម្ភាសដោយប្រើប្រាស់កម្រងសំណួរទៅតាមប្រភេទនីមួយៗ។

ដើម្បីសម្រេចបាននូវវត្ថុបំណងនៃការស្រាវជ្រាវ អ្នកស្រាវជ្រាវបានសម្រេចប្រើប្រាស់វិធីសាស្ត្រពីរប្រភេទក្នុងការចុះប្រមូលទិន្នន័យ គឺវិធីសាស្ត្រតាមបែបបរិមាណវិស័យ (Quantitative Method) និងវិធីសាស្ត្រតាមបែបគុណវិស័យ (Qualitative Method) ឬហៅម្យ៉ាងទៀតថាវិធីសាស្ត្រចម្រុះ(Mixed Methods)។ ទិន្នន័យដែលប្រមូលបានតាមរយៈកម្រងសំណួរ និងការសម្ភាសន៍ ត្រូវបានយកមកវិភាគក្នុងប្រព័ន្ធកុំព្យូទ័រតាមកម្មវិធី SPSS និង Excel។

លទ្ធផលនៃការស្រាវជ្រាវនេះបានបង្ហាញឱ្យឃើញថា មានបញ្ហាប្រឈមមួយចំនួននៅតែចោទជាបញ្ហាដល់ការបង្រៀន និងរៀនភាសាអង់គ្លេស។ វិធីសាស្ត្រដែលគ្រូប្រើញឹកញាប់ជាងគេនោះគឺវិធីសាស្ត្របកប្រែ ហើយក៏ជាវិធីសាស្ត្រដែលមានប្រសិទ្ធភាពបំផុតសម្រាប់ស្ថានភាពថ្នាក់រៀននាពេលបច្ចុប្បន្ននេះ ហើយគ្រូមួយចំនួនទៀតត្រូវបានប្រើប្រាស់ខុសឯកទេស ដែលជាបញ្ហាសម្រាប់ការបង្រៀន និងរៀន។

យោងតាមរបកគំហើញ និងសេចក្តីសន្និដ្ឋានលើប្រធានបទនេះអ្នកស្រាវជ្រាវមានសំណូមពរមួយចំនួនដូចខាងក្រោម៖

១. បណ្តុះបណ្តាលគ្រូភាសាអង់គ្លេសឱ្យបានគ្រប់ចំនួនតាមតម្រូវការ

២. បើកវគ្គបណ្តុះបណ្តាលបន្ថែមស្តីពីវិធីសាស្រ្តបង្រៀនជូនលោកគ្រូអ្នកគ្រូជាប្រចាំ

៣.សូមផ្តល់គ្រូភាសាអង់គ្លេស ទៅតាមសាលានីមួយៗឱ្យបានគ្រប់គ្រាន់និងទាន់ពេលវេលា

៤. ប្រើប្រាស់គ្រូឱ្យត្រូវតាមឯកទេសរបស់គាត់ដែលទទួលបានពីការបណ្តុះបណ្តាលពីសាលាគរុកោសល្យ។

លទ្ធផលស្រាវជ្រាវនេះ បាននាំដល់ការផ្តល់អនុសាសន៍ដើម្បីចូលរួមចំណែកពង្រឹងនូវវិធីសាស្រ្តបង្រៀនភាសាអង់គ្លេសរបស់លោកគ្រូ អ្នកគ្រូ និងធ្វើការកែលម្អឡើងវិញនូវបញ្ហាប្រឈមមួយចំនួនដែលកំពុងជួបប្រទះនាពេលបច្ចុប្បន្ននេះ។ លើសពីនេះទៀត អ្នកស្រាវជ្រាវក៏បានសំណូមពរសម្រាប់អ្នកសិក្សាស្រាវជ្រាវបន្ត នូវចំណុចសំខាន់ៗមួយចំនួនដែលពុំទាន់បានសិក្សាផងដែរ៕

# ABSTRACT

Education is universally recognized as a basic human right to gain knowledge, skills and attitudes as the Ministry of Education, Youth and Sport has begun reforming the education system since the beginning of the 5th mandate of the National Assembly 8 key strategies in the reform process.

A research study on situation of using English language teaching methods in lower secondary schools was designed to find out the situation of using English language teaching methods in lower secondary school.

The research is based on the theory and documentation of a number of educational institutions both nationally and internationally. The study was carried out at the lower secondary school in Phnom Penh. There, students in 7th, 8th and 9th grade and teachers who are teaching a number of English courses are targeted of using questionnaires in each category.

To achieve the objectives of the study, the researchers decided to use two types of data collection methods: the quantitative method and the qualitative method, or in other word is mix method. The collected data through questionnaires and interview were analyzed on a computerized basis through SPSS and Excel software.

The findings of the study show that there are still some challenges to teaching and learning English, such as teachers still using Grammar Translation Method with its effectiveness for large number of students in class. Some schools

Based on the above findings and conclusions, we as researchers on this topic have the following suggestions:

1. Train English teachers to the fullest extent requered.
2. Conduting training on teaching methods on a regular basis.
3. Provide sufficient English teacher in every school.
4. Put the teacher in to their specialist.

The findings led to recommendations to contribute to strengthening teachers'English language teaching methods and redefining some of the current challenges. In addition, the researchers also suggeted for later researchers a number of important aspects that have not yet been studied.

# មាតិកា

សេចក្តីប្រកាសរបស់បេក្ខជន ........................................ i

លិខិតបញ្ជាក់ ........................................ ii

សេចក្តីថ្លែងអំណរគុណ ........................................ iii

មូលន័យសង្ខេប ........................................ iv

ABSTRACT ........................................ vi

អក្សរសង្ខេប ........................................ xiii

**ជំពូកទី១៖ សេចក្តីផ្តើម** ........................................ ១

១.១. លំនាំបញ្ហានៃការស្រាវជ្រាវ ........................................ ១

១.១.១. បរិបទសកល ........................................ ១

១.១.២. បរិបទក្នុងតំបន់ ........................................ ២

១.១.៣. បរិបទកម្ពុជា ........................................ ២

១.២. ចំណោទបញ្ហានៃការស្រាវជ្រាវ ........................................ ៤

១.៣. គោលបំណងនៃការស្រាវជ្រាវ ........................................ ៤

១.៤. សំណួរស្រាវជ្រាវ ........................................ ៥

១.៥. សារៈសំខាន់នៃកាស្រាវជ្រាវ ........................................ ៥

១.៦. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ........................................ ៥

១.៦.១. វិសាលភាពនៃការស្រាវជ្រាវ ........................................ ៥

១.៦.២. ដែនកំណត់នៃការស្រាវជ្រាវ ........................................ ៦

១.៧.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ..................................................................................... ៦

**ជំពូកទី២៖ រំឭកទ្រឹស្តី**.................................................................................................... ៩

២.១. វិធីសាស្ត្រផ្ទាល់ (The Direct Method)............................................................................ ៩

២.២. វិធីសាស្ត្របកប្រែ (The Grammar Translation Method)............................................១០

២.៣. វិធីសាស្ត្របង្រៀនភាសាដោយចាក់សម្លេង (The Audio Lingual Method) ................ ១២

២.៤. វិធីសាស្ត្របង្រៀនភាសាដោយចាក់ភ្លេង (Suggestopedia) ..................................... ១២

២.៥. វិធីសាស្ត្របង្រៀនភាសាឱ្យរាងកាយទទួល (Total Physical Response) ....................១៥

២.៦. ការបង្រៀនភាសាបែបទំនាក់ទំនង (Communicative Language Teaching)..............១៦

២.៧.វិធីសាស្ត្ររៀនភាសាតាមបែបសហគមន៍ (Community Language Learning) ............១៨

២.៨.វិធីសាស្ត្របង្រៀនភាសាផ្អែកលើកិច្ចការ(Task Based Language Teaching) ............ ២១

២.៩. និយមន័យពាក្យគន្លឹះ ...........................................................................................២៤

**ជំពូកទី៣៖ វិធីសាស្ត្រស្រាវជ្រាវ** ...........................................................................................២៨

៣.១. ការរៀបចំការស្រាវជ្រាវ.........................................................................................២៨

៣.២. ឧបករណ៍ស្រាវជ្រាវ...............................................................................................២៩

៣.៣. វិធីសាស្ត្រជ្រើសរើសភាគសំណាក ..........................................................................២៩

៣.៤. ការប្រមូលទិន្នន័យ .............................................................................................. ៣០

៣.៤.១. ទំហំនៃភាគសំណាក និងមុខសញ្ញាដែលត្រូវយកទិន្នន័យ.................................. ៣០

៣.៤.២. ការសិក្សាសាកល្បង..........................................................................................៣១

៣.៥. ដំណាក់កាលនៃការប្រមូលទិន្នន័យ ................................................ ៣១

៣.៦. ការវិភាគទិន្នន័យ ................................................ ៣២

៣.៧. ក្រមសីលធម៌នៃការស្រាវជ្រាវ ................................................ ៣៣

**ជំពូកទី៤៖ លទ្ធផល និងការពិភាក្សា** ................................................ ៣៥

៤.១. លទ្ធផលស្រាវជ្រាវ ................................................ ៣៥

៤.១.១. ព័ត៌មានទូទៅ ................................................ ៣៥

៤.១.២. បច្ចេកទេសក្នុងការបង្រៀន ................................................ ៤១

៤.១.៣. ប្រសិទ្ធភាពនៃការបង្រៀនរបស់គ្រូ ................................................ ៥៣

៤.១.៤. ប្រសិទ្ធភាពនៃការបង្រៀនរបស់គ្រូ(សិស្ស) ................................................ ៥៨

៤.២. ការពិភាក្សា ................................................ ៦៣

៤.២.១. ឯកទេសរបស់គ្រូបង្រៀន ................................................ ៦៣

៤.២.២. ភាពញឹកញាប់នៃការប្រើប្រាស់វិធីសាស្ត្របង្រៀន ................................................ ៦៣

**ជំពូកទី៥៖ សេចក្តីសន្និដ្ឋាន និងសំណូមពរ** ................................................ ៦៩

៥.១. សេចក្តីសន្និដ្ឋាន ................................................ ៦៩

៥.២. សំណូមពរ ................................................ ៧០

៥.៣. ការសិក្សាស្រាវជ្រាវបន្ត ................................................ ៧០

**ឯកសារយោង** ................................................ ៧១

ឧបសម្ព័ន្ធទី១ ................................................ ៧៤

ឧបសម្ព័ន្ធទី២ ........................................................................................................ ៧៨

ឧបសម្ព័ន្ធទី៣ ........................................................................................................ ៨២

# បញ្ជីក្រាហ្វិក


ក្រាបទី១៖ ចំនួនសាលា និងគ្រូចូលរួម ........ ៣៥
ក្រាបទី២៖ ភេទ និងភាគរយគ្រូ ........ ៣៦
ក្រាបទី៣៖ កម្រិតវប្បធម៌ទូទៅរបស់គ្រូ ........ ៣៧
ក្រាបទី៤៖ កម្រិតបណ្តុះបណ្តាលវិជ្ជាជីវៈ ........ ៣៧
ក្រាបទី៥៖ ឯកទេសរបស់គ្រូបង្រៀន ........ ៣៨
ក្រាបទី៦៖ កម្រិសញ្ញាបត្រ ........ ៣៩
ក្រាបទី៧៖ បទពិសោធនៃការបង្រៀនភាសាអង់គ្លេស ........ ៣៩
ក្រាបទី៨៖ ចំនួនសាលា និងសិស្ស ........ ៤០
ក្រាបទី៩៖ ភេទ និងភាគរយសិស្សចូលរួម ........ ៤១
ក្រាបទី១០៖ វិធីសាស្រ្តផ្ទាល់(គ្រូ) ........ ៤១
ក្រាបទី១១៖ វិធីសាស្រ្តបកប្រែ(គ្រូ) ........ ៤២
ក្រាបទី១២៖ វិធីសាស្រ្តបង្រៀនភាសាដោយចាក់សម្លេង(គ្រូ) ........ ៤៣
ក្រាបទី១៣៖ វិធីសាស្រ្តបង្រៀនភាសាដោយចាក់ភ្លេង(គ្រូ) ........ ៤៣
ក្រាបទី១៤៖ វិធីសាស្រ្តបង្រៀនភាសាឱ្យរាងកាយទទួល(គ្រូ) ........ ៤៤
ក្រាបទី១៥៖ វិធីសាស្រ្តបង្រៀនភាសាតាមបែបទំនាក់ទំនង(គ្រូ) ........ ៤៤
ក្រាបទី១៦៖ វិធីសាស្រ្តបង្រៀនភាសាតាមបែបសហគមន៍(គ្រូ) ........ ៤៥
ក្រាបទី១៧៖ វិធីសាស្រ្តបង្រៀនភាសាផ្អែកលើកិច្ចការ(គ្រូ) ........ ៤៦
ក្រាបទី១៨៖ វិធីសាស្រ្តផ្ទាល់(សិស្ស) ........ ៤៧
ក្រាបទី១៩៖ វិធីសាស្រ្តបកប្រែ(សិស្ស) ........ ៤៨
ក្រាបទី២០៖ វិធីសាស្រ្តបង្រៀនភាសាដោយចាក់សម្លេង(សិស្ស) ........ ៤៨
ក្រាបទី២១៖ វិធីសាស្រ្តបង្រៀនភាសាដោយចាក់ភ្លេង(សិស្ស) ........ ៤៩
ក្រាបទី២២៖ វិធីសាស្រ្តបង្រៀនភាសាឱ្យរាងកាយទទួល(សិស្ស) ........ ៥០
ក្រាបទី២៣៖ វិធីសាស្រ្តបង្រៀនភាសាតាមបែបទំនាក់ទំនង(សិស្ស) ........ ៥១
ក្រាបទី២៤៖ វិធីសាស្រ្តបង្រៀនភាសាតាមបែបសហគមន៍(សិស្ស) ........ ៥២
ក្រាបទី២៥៖ វិធីសាស្រ្តបង្រៀនភាសាផ្អែកលើកិច្ចការ(សិស្ស) ........ ៥៣
ក្រាបទី២៦៖ កម្រិតនៃការចូលរួមក្នុងសកម្មភាពរៀន ........ ៥៣

ក្រាបទី២៧៖ កម្រិតខ្លឹមសារមេរៀនដែលសិស្សទទួលបាន ........ ៥៤
ក្រាបទី២៨៖ ចំណាប់អារម្មណ៍របស់សិស្សចំពោះការបង្រៀនភាសាអង់គ្លេស ........ ៥៥
ក្រាបទី២៩៖ ការរៀបចំសកម្មភាពរៀន ........ ៥៦
ក្រាបទី៣០៖ លទ្ធផលសិក្សារបស់សិស្ស ........ ៥៦
ក្រាបទី៣១៖ កម្រិតនៃការពេញចិត្តរបស់គ្រូចំពោះការបង្រៀន ........ ៥៧
ក្រាបទី៣២៖ ការចូលរួមក្នុងសកម្មភាពរៀនរបស់សិស្ស ........ ៥៨
ក្រាបទី៣៣៖ កម្រិតខ្លឹមសារមេរៀនដែលសិស្សទទួលបាន ........ ៥៨
ក្រាបទី៣៤៖ ចំណាប់អារម្មណ៍របស់សិស្សចំពោះការបង្រៀនភាសាអង់គ្លេស ........ ៥៩
ក្រាបទី៣៥៖ សកម្មភាពសិស្សរៀនក្នុងថ្នាក់ ........ ៦០
ក្រាបទី៣៦៖ លទ្ធផលសិក្សារបស់សិស្ស ........ ៦១
ក្រាបទី៣៧៖ ប្រៀបធៀបប្រសិទ្ធភាពនៃវិធីសាស្ត្រផ្ទាល់ និងវិធីសាស្ត្របកប្រែ ........ ៦១
ក្រាបទី៣៨៖ កម្រិតនៃការពេញចិត្តរបស់សិស្សចំពោះការរៀនភាសាអង់គ្លេស ........ ៦២

# អក្សរសង្ខេប

១. DM : The Direct Method (វិធីសាស្ត្រផ្ទាល់)

២. GTM : The Grammar Translation Method (វិធីសាស្ត្របកប្រែ)

៣. L1 : First Language (ភាសាទីមួយ ឬ ភាសាកំណើត)

៤. ALM : The Audio Lingual Method (វិធីសាស្ត្របង្រៀនភាសាបែបចាក់សម្លេង)

៥. TPR : The Total Physical Response (វិធីសាស្ត្របង្រៀនភាសាឱ្យរាងកាយទទួល)

៦. CLT : Communicative Language Teaching (វិធីសាស្ត្របង្រៀនភាសាបែបទំនក់ទំនង)

៧. CLL : Community Language Learning (វិធីសាស្ត្របង្រៀនភាសាបែបសហគមន៍)

៨. TBLT : Task Based Language Teaching(វិធីសាស្ត្របង្រៀនភាសាផ្តោតលើកិច្ចការ)

៩. L2 : Second Language (ភាសាទីពីរ)

# ជំពូកទី១

# សេចក្តីផ្តើម

# ជំពូកទី១៖ សេចក្តីផ្តើម

## ១.១. លំនាំបញ្ហានៃការស្រាវជ្រាវ

### ១.១.១. បរិបទសកល

ភាសាអង់គ្លេស ជាភាសាមួយក្នុងចំណោមភាសាបរទេសដទៃទៀត(ក្រៅពីភាសាជាតិ) ដែលត្រូវបានមនុស្សទូទៅជុំវិញពិភពលោកទទួលស្គាល់ និងប្រើប្រាស់យ៉ាងទូលំទូលាយនៅក្នុងគោលបំណងផ្សេងៗគ្នានាពេលបច្ចុប្បន្ននេះ។ ដោយយោងទៅតាមលោក Harmer (2007) បានបែងចែកពិភពលោកជាបីផ្នែកខាងការប្រើប្រាស់ភាសាអង់គ្លេស ដែលផ្នែកទីមួយរួមមានប្រទេសអង់គ្លេស សហរដ្ឋអាមេរិក អូស្ត្រាលី ជាដើមបានប្រកាន់យកភាសាអង់គ្លេសជាភាសាកំណើត។ ផ្នែកទីពីរ រួមមានប្រទេសឥណ្ឌា នីហ្សេរីយ៉ា សឹង្ហបូរី បានប្រកាន់យកភាសាអង់គ្លេសជាភាសាផ្លូវការទីពីរ។ រីឯផ្នែកទីបីវិញ តំណាងឱ្យប្រទេសមួយភាគបីដទៃទៀតរួមមាន ប៉ូឡូញ ជប៉ុន ម៉ិចស៊ិចកូ ហុងហ្គារី ជាដើមបានប្រើប្រាស់ភាសាអង់គ្លេសជាភាសាបរទេស។ លោក Harmer (2007) ថា អ្នកនិយាយភាសាអង់គ្លេសនឹងកើនដល់ចំនួនបីពាន់លាននាក់នៅឆ្នាំ ២០៤០ ដែលតំណាងឱ្យ៤០ភាគរយនៃប្រជាជនពិភពលោកដែលអាចប្រើប្រាស់ភាសាអង់គ្លេសបានក្នុងកម្រិតខ្ពស់។ ជាមួយគ្នានិងការរីកចម្រើនឥតឈប់ឈរផ្នែកបច្ចេកវិទ្យា និងការទំនាក់ទំនងក្នុងសតវត្សទី២១នេះ ឯកសារសំខាន់ៗជាច្រើន ត្រូវបានអ្នកនិពន្ធរៀបចំតាក់តែងឡើងដោយប្រើប្រាស់ភាសាអង់គ្លេសនេះជាគោល ក្នុងគោលបំណងចែករំលែកបទពិសោធ ចំណេះដឹង និងជំនាញផ្សេងៗដល់អ្នកសិក្សាស្រាវជ្រាវដទៃទៀត ដែលមានចំណាប់អារម្មណ៍លើការស្រាវជ្រាវរបស់ខ្លួន។ ម្យ៉ាងវិញទៀត ភាសានេះ ត្រូវបានគេប្រើប្រាស់ក្នុងការប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមកពីទ្វីបមួយទៅទ្វីបមួយ ពីតំបន់មួយទៅតំបន់មួយ ពីកន្លែងមួយទៅកន្លែងមួយទៀតប្រកបដោយភាពរលូនជានិច្ច។ ទោះបីមានប្រទេសមួយចំនួនមិនចាប់អារម្មណ៍ នឹងការរៀនភាសាអង់គ្លេសនេះក៏ដោយក៏មានប្រទេសដទៃទៀតបានអនុញ្ញាតឱ្យប្រជានជនរបស់ខ្លួនរៀនដោយសេរីផងដែរ។

ទន្ទឹមនឹងការរីកចម្រើននៃការប្រើប្រាស់ភាសាអង់គ្លេសនេះ រដ្ឋាភិបាលនៃប្រទេសមួយចំនួននៅលើសកលលោក បានយកចិត្តទុកដាក់ក្នុងការបណ្តុះបណ្តាលប្រជានជនរបស់ខ្លួនប្រកបដោយគុណភាពផងដែរ។ ក្រសួងអប់រំដែលជាសេនាធិការរបស់រដ្ឋាភិបាលដែលទទួល

ខុសត្រូវក្នុងការបណ្តុះបណ្តាលប្រជាជនរបស់ខ្លួនបានកំពុងនឹងបន្តយកចិត្តទុកដាក់នៅលើ វិស័យអប់រំយ៉ាងខ្លាំង។ លោកគ្រូ អ្នកគ្រូគឺជាធនធាននៃចំណេះដឹងដែលមិនចេះរីងស្ងួតសម្រាប់ការអប់រំនោះ។ ជាមួយគ្នានេះ ក្រសួងអប់រំបានយកចិត្តទុកដាក់ក្នុងការបណ្តុះបណ្តាល និងបំប៉នដល់លោកគ្រូ អ្នកគ្រូលើវិធីសាស្រ្តថ្មីៗក្នុងការអប់រំយុវជនជំនាន់ក្រោយដែលជាទំពាំងស្នងឫស្សី និងជាសរសរទ្រូងដ៏រឹងមាំសម្រាប់ការអភិវឌ្ឍប្រទេសជាតិឱ្យរីកចម្រើនដូចប្រទេសនានានៅលើសកលលោក។

## ១.១.២. បរិបទក្នុងតំបន់

ជាមួយនឹងការរីកចម្រើនផ្នែកសេដ្ឋកិច្ច ការទំនាក់ទំនងក្នុងតំបន់ និងពិភពលោក ប្រជាជននៅក្នុងភូមិភាគអាស៊ីភាគអាគ្នេយ៍ ក៏បានសម្លឹងឃើញពីសក្តានុពលនៃការប្រើប្រាស់ភាសាអង់គ្លេសនេះជាចាំបាច់ផងដែរ។ រដ្ឋាភិបាល នៃប្រទេសនីមួយៗនៅក្នុងតំបន់ក៏នឹងកំពុងប្រឹងប្រែងរៀបចំធ្វើការកែទម្រង់គោលនយោបាយអប់រំប្រជាពលរដ្ឋរបស់ខ្លួនដើម្បីឆ្លើយតបទៅនឹងការរីកចម្រើនយ៉ាងលឿនរបស់ពិភពលោក។ ការអប់រំ គឺជាឆ្អឹងខ្នងដ៏រឹងមាំដែលអាចជួយឱ្យសង្គមមានការរីកចម្រើន គ្រួសារមានជីវភាពធូរធារ និងប្រាក់ចំណូលសមរម្យ។ ការអប់រំគឺជាវិធីតែមួយគត់ដែលអាចផ្លាស់ប្តូរផ្នត់គំនិតរបស់បុគ្គលម្នាក់ៗទៅរកការគិតបែបវិជ្ជមាន ទើបអាចផ្លាស់ប្តូរសង្គមឱ្យកាន់តែរីកចម្រើនបាន។ ការបង្រៀន និងរៀនគឺជាកត្តាមួយដ៏សំខាន់នៅក្នុងដំណើរការអប់រំដើម្បីឈានទៅរកភាពជោគជ័យនាពេលអនាគត។ ការបង្រៀន និងរៀនអាចជួយឱ្យសិស្សទទួលបាននូវចំណេះដឹង ជំនាញថ្មីៗដើម្បីបង្កើនសមត្ថភាពរបស់ខ្លួនក្នុងការប្រគួតប្រជែងដើម្បីដណ្តើមយកទីផ្សារការងារនាពេលបច្ចុប្បន្ននៅក្នុងសង្គមដែលកំពុងតែរីកលូតលាស់ឥតឈប់ឈរ។ ម្យ៉ាងវិញទៀត ការអប់រំផ្នែកភាសាអង់គ្លេសត្រូវបានពួកគេផ្តោតការយកចិត្តទុកដាក់ខ្ពស់ ដើម្បីឱ្យពលរដ្ឋរបស់ខ្លួនមានសមត្ថភាពពេញលេញក្នុងការប្រើប្រាស់ភាសាអង់គ្លេសដើម្បីបំពេញការងាររបស់ខ្លួន ក្នុងគោលបំណងអភិវឌ្ឍប្រទេសជាតិឱ្យមានការរីកចម្រើនដូចប្រទេសនៅក្នុងតំបន់និងពិភពលោក។

## ១.១.៣. បរិបទកម្ពុជា

ប្រទេសកម្ពុជាគឺជាប្រទេសមួយនៅភូមិភាគអាស៊ី នឹងជាសមាជិកនៃសមាគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍(អាស៊ាន)នេះដែរនោះ ក៏ទទួលរងនូវឥទ្ធិពលនៃការប្រើប្រាស់ភាសាបរទេស

ជាសកលនេះដែរ ជាពិសេសភាសាអង់គ្លេសនេះឯង។ ដើម្បីឆ្លើយតបទៅនឹងការរីកចម្រើនរបស់ប្រទេស និងដើម្បីបំពេញសេចក្តីត្រូវការរបស់ប្រជាជនកម្ពុជាក្នុងការរៀនភាសាអង់គ្លេស រាជរដ្ឋាភិបាលកម្ពុជាដែលមានក្រសួងអប់រំ យុវជន និងកីឡា ជាសេនាធិការរបស់ខ្លួនបានដាក់ចេញនូវគោលនយោបាយអប់រំជាតិ ព្រមទាំងរៀបចំផែនការជាយុទ្ធសាស្ត្រដើម្បីធ្វើកំណែទម្រង់ជាបន្តបន្ទាប់នាប៉ុន្មានឆ្នាំចុងក្រោយនេះ។ ជាពិសេសក្រសួងអប់រំបានដាក់ឱ្យចាប់ផ្តើមអនុវត្តកម្មវិធីសិក្សាភាសាអង់គ្លេសចាប់ពីថ្នាក់ទី៤ នៅឆ្នាំ២០១៤ ដើម្បីឱ្យសិស្សានុសិស្សដែលជាទំពាំងស្នងឫស្សីសម្រាប់ការអភិវឌ្ឍប្រទេសទាំងនោះ មានមូលដ្ឋានគ្រឹះភាសាអង់គ្លេសក្នុងការបណ្តុះបណ្តាលបន្ត។ ភាសាអង់គ្លេសគឺជាភាសាបរទេសមួយក្នុងចំណោមភាសាបរទេសដទៃទៀតដែលកំពុងប្រើប្រាស់យ៉ាងទូលំទូលាយ និងដោយសេរីនៅក្នុងប្រទេសកម្ពុជា ដែលជាទីចាប់អារម្មណ៍របស់ប្រជាជនទូទៅក្នុងសង្គមខ្មែរ ជាពិសេសក្នុងចំណោមអ្នកសិក្សាទូទៅ។ សាលារដ្ឋ និងសាលាឯកជនជាច្រើនបានកំពុងរីកចម្រើនដូចផ្សិតទាំងនៅទីក្រុង និងជនបទដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់អ្នកសិក្សាទាំងនោះ។ អាណាព្យាបាលមួយចំនួនដែលមានលទ្ធភាពគ្រប់គ្រាន់បានកំពុងស្វែងរកសាលាល្បីៗ គ្រូល្អៗ ដើម្បីឱ្យកូនៗរបស់ពួកគាត់ទទួលបានការអប់រំភាសាអង់គ្លេសនេះកាន់តែប្រសើរឡើងផងដែរ។ ពួកគាត់គិតថា នៅពេលដែលបុត្រធីតារបស់ពួកគាត់ទទួលបានការអប់រំផ្នែកភាសាអង់គ្លេសនេះ កាន់តែខ្ពស់នោះ ពួកគេមានឱកាសទទួលបានការងារល្អៗនៅក្នុងទីផ្សារការងារនាពេលបច្ចុប្បន្ន និងទៅអនាគត។

វិធីសាស្ត្របង្រៀនគឺជាសមាសធាតុមួយដ៏សំខាន់ដើម្បីអនុវត្តគោលដៅនៃការអប់រំ នៅក្នុងដំណើរការនៃការបង្រៀន និងរៀនជាពិសេសនោះគឺថ្នាក់រៀនភាសាអង់គ្លេស (Natsir, 2014, p. 58)។ ដើម្បីឱ្យការបង្រៀននិងរៀនទទួលបានជោគជ័យវាទាមទារឱ្យគ្រូបង្រៀនមានគុណវុឌ្ឍិគ្រប់គ្រាន់ និងវិធីសាស្ត្របង្រៀនច្បាស់លាស់ដែលមានលក្ខណៈបត់បែនទៅតាមស្ថានភាពថ្នាក់រៀនសម្រាប់បង្រៀនសិស្ស។ ក្រសួងអប់រំ យុវជន និងកីឡា បាននឹងកំពុងធ្វើការងារជាច្រើនដើម្បីលើកកម្ពស់គុណវុឌ្ឍិរបស់គ្រូបង្រៀនតាមរយៈការ បណ្តុះបណ្តាលបុគ្គលិកបង្រៀនជារៀងរាល់ឆ្នាំទៅលើវិធីសាស្ត្របង្រៀនថ្មីៗ ដើម្បីឆ្លើយតបទៅនឹងការរីកចំម្រើនរបស់សង្គមនាពេលបច្ចុប្បន្ន។

## ១.២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ទោះបីជាមានការខិតខំប្រឹងប្រែងរបស់ក្រសួងអប់រំ យុវជន និងកីឡា យ៉ាងនេះក៏ដោយ អ្នកសិក្សាស្រាវជ្រាវបានសង្កេតឃើញថា នៅតែមានសិស្សានុសិស្សមួយចំនួនតូចមិនទាន់បានទទួលនូវការអប់រំផ្នែកភាសាអង់គ្លេសនេះឱ្យបានស៊ីជម្រៅ និងមិនសូវចូលចិត្ត និងចាប់អារម្មណ៍រៀនភាសាអង់គ្លេសនេះនៅឡើយដែរ។ កត្តានេះហើយដែលជាចំណុចខ្វាយខ្វល់របស់ថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំយុវជននិងកីឡាគ្រប់រាជធានីខេត្តក្រុង គណៈគ្រប់គ្រងសាលា លោកគ្រូ អ្នកគ្រូ មាតាបិតា អាណាព្យាបាលរបស់សិស្សានុសិស្សផងដែរ។ ដូចនេះការបង្រៀន និងរៀន ជាប្រធានបទយ៉ាងសំខាន់សម្រាប់ការស្រាវជ្រាវ និងជាទីចាប់អារម្មណ៍របស់អ្នកស្រាវជ្រាវទូទៅ ជាពិសេសគឺអ្នកសិក្សាស្រាវជ្រាវផ្នែកអប់រំ ដែលផ្តោតយ៉ាងសំខាន់ទៅលើ វិធីសាស្រ្តក្នុងការបង្រៀនភាសាអង់គ្លេសនេះឯង។ ការស្រាវជ្រាវបានធ្វើឡើងជាបន្តបន្ទាប់ ក្នុងគោលបំណងស្វែងរកចំណុចសកម្មណាខ្លះដែលទទួលបានជោគជ័យសម្រាប់ដក់ស្រង់ទុកជាបទពិសោធដើម្បីចែកចាយដល់អ្នកជំនាន់ក្រោយ ហើយចំណុចអសកម្មណាខ្លះដែលនៅខ្វះចន្លោះត្រូវការបំពេញបន្ថែមដើម្បីជួយឱ្យ ការបង្រៀនរបស់លោកគ្រូ អ្នកគ្រូ និងការរៀនភាសាអង់គ្លេសរបស់សិស្សានុសិស្សកាន់តែមានប្រសិទ្ធភាពខ្ពស់មួយកម្រិតថែមទៀត។ ការស្រាវជ្រាវនេះ បានផ្តោតសំខាន់ទៅលើភាពញឹកញាប់នៃការប្រើប្រាស់វិធីសាស្រ្តបង្រៀនភាសាអង់គ្លេសនៅមធ្យមសិក្សាបឋមភូមិ ដែលគ្រូបង្រៀនប្រើក្នុងការបង្រៀនសិស្ស នឹងស្វែងរកឱ្យឃើញនូវប្រសិទ្ធភាពរបស់វិធីសាស្រ្តនោះ ដែលលោកគ្រូ អ្នកគ្រូប្រើប្រាស់ក្នុងការបង្រៀន និងរៀនភាសាអង់គ្លេស។

## ១.៣. គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះមានគោលបំណងសំខាន់ពីរគឺដើម្បី ៖

១. រកឱ្យឃើញវិធីសាស្រ្តដែលគ្រូភាសាអង់គ្លេសប្រើប្រាស់ញឹកញាប់ជាងគេ ក្នុងការបង្រៀនសិស្ស។

២. សិក្សាពីប្រសិទ្ធភាពដែលគ្រូភាសាអង់គ្លេសប្រើប្រាស់នូវវិធីសាស្រ្តនោះ។

## ១.៤. សំណួរស្រាវជ្រាវ

ផ្អែកទៅលើគោលបំណងនៃការសិក្សាស្រាវជ្រាវទាំងពីរខាងលើ អ្នកស្រាវជ្រាវអាចចោទជាសំណួរចំនួនពីរដូចខាងក្រោមៈ

១.តើវិធីសាស្ត្រណាមួយដែលគ្រូភាសាអង់គ្លេសប្រើប្រាស់ញឹកញាប់ជាងគេ ក្នុងការបង្រៀនសិស្ស?

២. តើវិធីសាស្ត្រដែលគ្រូប្រើញឹកញាប់ជាងគេក្នុងការបង្រៀនសិស្សនោះ មានប្រសិទ្ធភាពយ៉ាងដូចម្តេចដែរ?

## ១.៥. សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ មានសារៈសំខាន់សម្រាប់ជួយឱ្យគ្រូបង្រៀនភាសាអង់គ្លេសថ្នាក់ទី៧ ថ្នាក់ទី៨ និងថ្នាក់ទី៩ ដើម្បីឱ្យការបង្រៀនមានប្រសិទ្ធភាព ព្រមទាំងប្រើប្រាស់នូវវិធីសាស្ត្រមួយចំនួនដែលធ្វើឱ្យសិស្សថ្នាក់ទី៧ ថ្នាក់ទី៨ និងថ្នាក់ទី៩ ផ្លាស់ប្តូរឥរិយាបថនិងយកចិត្តទុកដាក់រៀនភាសាអង់គ្លេស តាមវិធីសាស្ត្រត្រឹមត្រូវ នឹងមានប្រសិទ្ធភាពបំផុត។ ម្យ៉ាងវិញទៀត ការសិក្សាស្រាវជ្រាវនេះ អាចជួយបំពេញនូវចន្លោះប្រហោងរបស់គ្រូបង្រៀនភាសាអង់គ្លេសនៅមធ្យមសិក្សាបឋមភូមិក្នុងការជ្រើសរើសវិធីសាស្ត្របង្រៀនត្រឹមត្រូវ ដែលសមស្របទៅនឹងស្ថានភាពថ្នាក់រៀននាពេលបច្ចុប្បន្ន ដើម្បីទាក់ទាញចំណាប់អារម្មណ៍របស់សិស្សក្នុងការបង្រៀន និងរៀនភាសាអង់គ្លេសនាពេលបច្ចុប្បន្ន និងទៅអនាគត។ បន្ថែមលើនេះទៀត ការសិក្សាស្រាវជ្រាវនេះអាចជួយបំពេញចិត្តរបស់ឪពុកម្តាយ អាណាព្យាបាលរបស់សិស្ស ដែលចង់ឱ្យកូនៗរបស់ខ្លួនទទួលបានការអប់រំផ្នែកភាសាអង់គ្លេសនេះបានកាន់តែល្អប្រសើរឡើងសម្រាប់ការសិក្សាបន្តទៀត។

## ១.៦. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

### ១.៦.១. វិសាលភាពនៃការស្រាវជ្រាវ

វិសាលភាពនៃការស្រាវជ្រាវ គ្របដណ្តប់តែលើសាលាមធ្យមសិក្សាបឋមភូមិនៅក្នុងរាជធានីភ្នំពេញចាប់ពីថ្នាក់ទី៧ ថ្នាក់ទី៨ និងថ្នាក់ទី៩ប៉ុណ្ណោះ ដែលមានគ្រូបង្រៀនភាសាអង់គ្លេសដែលកំពុងបង្រៀនភាសាអង់គ្លេសនៅតាមសាលាក្នុងរាជធានីភ្នំពេញ លើការប្រើប្រាស់វិធីសាស្ត្របង្រៀន និងប្រសិទ្ធភាពរបស់វិធីសាស្ត្រដែលលោកគ្រូ អ្នកគ្រូ កំពុងប្រើ

ប្រាស់នោះ។ អ្នកសិក្សាស្រាវជ្រាវនឹងធ្វើការសម្ភាសជាមួយលោកគ្រូ អ្នកគ្រូ ដែលកំពុងបង្រៀនភាសាអង់គ្លេសព្រមទាំងបំពេញកម្រងសំណួរ។ រីឯសិស្សានុសិស្សនៅតាមសាលាគោលដៅ អ្នកសិក្សាស្រាវជ្រាវបានសុំឱ្យជួយបំពេញកម្រងសំណួរដែលបញ្ជាក់ពីភាពញឹកញាប់ និងប្រសិទ្ធភាពនៃការប្រើប្រាស់វិធីសាស្ត្របង្រៀនភាសាអង់គ្លេសផងដែរ។

## ១.៦.២. ដែនកំណត់នៃការស្រាវជ្រាវ

អាស្រ័យដោយពេលវេលា ឯកសារ និងធនធានមានកំណត់ អ្នកសិក្សាស្រាវជ្រាវមិនអាចសិក្សាបាននូវគ្រប់បញ្ហាទាំងឡាយដែលគ្រូបង្រៀនភាសាអង់គ្លេសទាំងអស់កំពុងតែជួបប្រទះនាពេលបច្ចុប្បន្ននោះទេ។ អ្នកសិក្សាស្រាវជ្រាវសិក្សាតែលើវិធីសាស្ត្របង្រៀនដែលលោកគ្រូ អ្នកគ្រូ ជ្រើសរើសមកប្រើប្រាស់ញឹកញាប់ជាងគេក្នុងការបង្រៀនដែលវិធីសាស្ត្រទាំងនោះមានដូចជា ១.វិធីសាស្ត្រផ្ទាល់ (Direct Method) ២.វិធីសាស្ត្របកប្រែ (Grammar Translation Method) ៣.វិធីសាស្ត្របង្រៀនភាសាបែបចាក់សម្លេង (Autio Lingual Method) ៤. វិធីសាស្ត្របង្រៀនភាសាបែបចាក់ភ្លេង (Suggestopedia) ៥.វិធីសាស្ត្របង្រៀនភាសាបែបឱ្យរាងកាយទទួល (Total Physical Response) ៦.វិធីសាស្ត្របង្រៀនភាសាបែបទំនាក់ទំនង (Communicative Language Teaching) ៧. វិធីសាស្ត្ររៀនភាសាបែបសហគមន៍ (Community Language Learning) ៨.វិធីសាស្ត្របង្រៀនភាសាផ្អែកលើកិច្ចការ (Task Based Language Teaching) និងប្រសិទ្ធភាពរបស់វិធីសាស្ត្រទាំងនេះតែប៉ុណ្ណោះ។ ជាមួយគ្នានេះដែរ ដោយសារសាលាអនុវិទ្យាល័យនៅក្នុងរាជធានីភ្នំពេញមានចំនួនរហូតដល់ទៅ ៣០សាលា ក្នុងឆ្នាំសិក្សា២០១៨-២០១៩ នោះអ្នកសិក្សាស្រាវជ្រាវ ក៏មិនអាចសិក្សាស្រាវជ្រាវបានគ្រប់សាលានោះទេគឺ អ្នកសិក្សាស្រាវជ្រាវបានជ្រើសរើសយកតែសាលាគោលដៅចំនួន ១២ សាលាតែប៉ុណ្ណោះក្នុងចំណោមសាលាទាំងអស់នោះមកធ្វើការសិក្សាស្រាវជ្រាវ គឺសាលាអនុវិទ្យាល័យនៅកណ្តាលក្រុងចំនួន០៤សាលា សាលាអនុវិទ្យាល័យនៅជាយក្រុងចំនួន ០៤ សាលា និងសាលាអនុវិទ្យាល័យនៅតំបន់ដាច់ស្រយាលចំនួន ០៤សាលា។

## ១.៧.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ ចែកចេញជាប្រាំជំពូកធំៗគឺះ

**ជំពូកទី១ះ សេចក្តីផ្តើម**

ក្នុងជំពូកនេះ អ្នកសិក្សាស្រាវជ្រាវនឹងលើកឡើងពីលំនាំបញ្ហានៃការស្រាវជ្រាវ ចំណោទបញ្ហានៃការស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ សំណួរស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ។

**ជំពូកទី២៖ រំឭកទ្រឹស្តី**

ក្នុងជំពូកនេះ អ្នកសិក្សាស្រាវជ្រាវបានប្រមូលយកទ្រឹស្តីចាស់ៗពីអ្នកសិក្សាស្រាវជ្រាវមុនៗដែលមានខ្លឹមសារពាក់ព័ន្ធទៅនឹងប្រធានបទនេះ ដែលជាពិសេសនោះគឺទ្រឹស្តីដែលទាក់ទងទៅនឹងភាពញឹកញាប់នៃការប្រើប្រាស់វិធីសាស្ត្របង្រៀនភាសាអង់គ្លេស របស់គ្រូបង្រៀន និងប្រសិទ្ធភាពរបស់វិធីសាស្ត្រនោះដើម្បីធ្វើជាគំនិតសម្រាប់ធ្វើការសិក្សាស្រាវជ្រាវ និងប្រៀបធៀបទៅនឹងលទ្ធផលដែលបានរកឃើញ។

**ជំពូកទី៣៖ វិធីសាស្ត្រស្រាវជ្រាវ**

ក្នុងជំពូកនេះ អ្នកសិក្សាស្រាវជ្រាវ នឹងបង្ហាញពីឧបករណ៍សម្រាប់ការស្រាវជ្រាវ វិធីសាស្ត្រសម្រាប់ការប្រមូលទិន្នន័យ វិធីសាស្ត្រក្នុងការជ្រើសរើសភាគសំណាក និងវិធីសាស្ត្រក្នុងការវិភាគទិន្នន័យជាដើម។

**ជំពូកទី៤៖ លទ្ធផល និងការពិភាក្សា**

ក្នុងជំពូកនេះ អ្នកស្រាវជ្រាវនឹងលើកឡើងពីលក្ខណៈជាក់ស្តែងនៃលទ្ធផលដែលអ្នកសិក្សាស្រាវជ្រាវបានធ្វើការសិក្សាស្រាវជ្រាវតាមរយៈ ឯកសារស្រាវជ្រាវនានា លទ្ធផលនៃការសម្ភាសន៍ និងចម្លើយក្នុងកម្រងសំណួរដែលត្រូវបានបំពេញដោយសំណាក ដើម្បីធ្វើការប្រៀបធៀបទៅនឹងទ្រឹស្តីដែលបានរំឭកនៅក្នុងជំពូកទី២ ហើយឆ្លើយតបទៅនឹងចំណោទបញ្ហាដែលបានចោទសួរ ក្នុងគោលបំណងវិភាគឱ្យឃើញនូវប្រសិទ្ធភាពនៃការប្រើប្រាស់វិធីសាស្ត្រញឹកញាប់ ដែលគ្រូបង្រៀនភាសាអង់គ្លេសសម្រេចចិត្តជ្រើសរើសយកមកប្រើក្នុងម៉ោងបង្រៀនរបស់ខ្លួន។

**ជំពូកទី៥៖ សេចក្តីសន្និដ្ឋាន និងសំណូមពរ**

ជាជំពូកចុងក្រោយនៃការសិក្សាស្រាវជ្រាវ អ្នកសិក្សាស្រាវជ្រាវនឹងទាញយកសេចក្តីសន្និដ្ឋាន ពីលទ្ធផលនៃការសិក្សាស្រាវជ្រាវរបស់ខ្លួនដែលបានរកឃើញ និងលើកជាសំណូមពរមួយចំនួន លើចំណុចដែលត្រូវកែលម្អសម្រាប់ការជ្រើសរើសវិធីសាស្ត្របង្រៀនភាសាអង់គ្លេសដែលសមស្រប នឹងមានប្រសិទ្ធភាពសម្រាប់ការបង្រៀននិងរៀនរបស់សិស្ស។

# ជំពូកទី២

# រំឭកទ្រឹស្តី

# ជំពូកទី២៖ រំឭកទ្រឹស្តី

## ២.១. វិធីសាស្ត្រផ្ទាល់ ( The Direct Method )

ការអភិវឌ្ឍភាសានិយាយបានដើរតួនាទីយ៉ាងសំខាន់ ក្នុងដំណើរការសិក្សាភាសាបរទេស។ ភាពស្ទាត់ជំនាញក្នុងការនិយាយត្រូវបានគេពិចារណាទៅលើគោលដៅ នៃការរៀនភាសាបរទេសផងដែរ។ មានសេចក្តីសន្និដ្ឋានមួយថាភាសាដែលត្រូវបានគេរៀនយ៉ាងល្អបំផុតនោះគឺនៅពេលដែលសិស្សទាំងអស់ប្រើប្រាស់វាយ៉ាងសកម្មនៅក្នុងថ្នាក់រៀន។ វិធីសាស្ត្រផ្ទាល់ (Direct Method) ដែលត្រូវបានគេទទួលស្គាល់ថាជាវិធីសាស្ត្រធម្មជាតិ ឬវិធីសាស្ត្រសន្ទនាមានប្រជាប្រិយភាព នៅពេលដែលវាអាចធ្វើឱ្យសិស្សានុសិស្សអាចទំនាក់ទំនងគ្នាបានដោយប្រើប្រាស់ភាសាទីពីរដែលពួកគេកំពុងតែរៀន។ វិធីសាស្ត្រផ្ទាល់បានផ្តោតសំខាន់ទៅលើការប្រើប្រាស់ភាសាប្រចាំថ្ងៃ ការប្រើប្រាស់សំណួរ និងចម្លើយដែលសង្កត់ធ្ងន់ទៅលើខ្លឹមសារមេរៀននៅក្នុងការបង្រៀនភាសានិយាយ (Mart, 2013)។ វិធីសាស្ត្រផ្ទាល់ត្រូវបានគេប្រើដើម្បីឱ្យមានទំនាក់ទំនងគ្នារវាងអត្ថន័យនិងខ្លឹមសារមេរៀនរបស់វា នៅក្នុងថ្នាក់រៀនចៀសវាងមិនឱ្យសិស្សប្រើប្រាស់ភាសាទីមួយរបស់ខ្លួន និងការបកប្រែពីភាសាទីមួយទៅភាសាទីពីរដែលនាំឱ្យសិស្សឈានទៅរកភាពស្ទាត់ជំនាញ ហើយគេប្រើវាជាមធ្យោបាយនៃការណែនាំឬទំនាក់ទំនង។ លោក Brown, (2000) បានបង្ហាញពីគោលការណ៍នៃវិធីសាស្ត្រផ្ទាល់ដូចខាងក្រោម៖

១. ខ្លឹមសារមេរៀនត្រូវបានគេយកមកប្រើក្នុងការណែនាំក្នុងថ្នាក់រៀន

២. ជ្រើសរើសយកពាក្យ និងឃ្លាប្រើប្រាស់ប្រចាំថ្ងៃមកបង្រៀន

៣. ជំនាញក្នុងការទំនាក់ទំនងផ្ទាល់ត្រូវបានគេបង្កើតឡើងតាមរយៈ ការពិភាក្សាក្រុមគ្រូ និងសិស្ស

៤. វេយ្យាករណ៍ត្រូវបានបង្រៀនតាមរបៀបពន្យល់រួចទាញជាទ្រឹស្តី

៥. ចំណុចថ្មីៗត្រូវបានគេបង្រៀនតាមរយៈការធ្វើជាគំរូ និងការអនុវត្ត

៦. ពាក្យថ្មីត្រូវបានបង្រៀនតាមរយៈរូបភាព ការពន្យល់ ឬវត្ថុផ្សេងៗ

៧. សមត្ថភាពនិយាយ និងការស្តាប់ត្រូវបានគេបង្រៀន

៨. សង្កត់ធ្ងន់ទៅលើការបញ្ចេញសម្លេងត្រឹមត្រូវនិងវេយ្យាករណ៍

វិធីសាស្រ្តផ្ទាល់ មិនមានដំណើរការល្អទេនៅក្នុងការអប់រំសាធារណៈព្រោះវាត្រូវការចំណាយលុយ ពេលវេលា និងចំណេះដឹងគ្រូធ្វើឱ្យវិធីសាស្រ្តនេះពិបាកប្រើ (Brown, 2000)។

## ២.២. វិធីសាស្រ្តបកប្រែ ( The Grammar Translation Method )

វិធីសាស្រ្តបង្រៀនតាមបែបបកប្រែគឺ ជាវិធីសាស្រ្តមួយដែលត្រូវបានគេប្រើចាប់តាំងពីសតវត្សទី១៩មកម្លេះ។ វិធីសាស្រ្តនេះមានប្រជាប្រិយភាពបំផុតក្នុងចំណោមវិធីសាស្រ្តដទៃទៀត (Natsir, 2014)។ វិធីសាស្រ្តនេះមានលក្ខណៈខុសគ្នាដាច់ពីវិធីសាស្រ្តបង្រៀនភាសាបែបទំនាក់ទំនង (CLT) ដោយវាបានបង្រៀនឱ្យសិស្សចេះវិភាគភាសា ជួយឱ្យសិស្សក្នុងការអានស្នារដៃអក្សរសិល្ប៍ ជាជាងឱ្យសិស្សប្រើប្រាស់ភាសា។ វិធីសាស្រ្តបង្រៀនតាមបែបបកប្រែ ១.បង្រៀនដោយប្រើប្រាស់ភាសាកំណើត (L1)។ ២.បង្រៀនពាក្យដោយបកប្រែទៅជាភាសកំណើត។ ៣.សិស្សត្រូវតែយល់ពីវេយ្យករណ៍មុននឹងអាចសរសេរឃ្លាប្រយោគបាន។ ៤.សម្ភារៈឧបទ្ទេសត្រូវបានផលិតដោយគ្រូដូចនេះសិស្សមិនមានភាពស៊ាំទៅនឹងសម្ភារៈទាំងនោះទេ។ ៥.សិស្សមិនត្រូវបានគេបង្ហំឱ្យប្រើប្រាស់ភាសាទីពីរក្នុងការទំនាក់ទំនងទេ។ នៅក្នុងវិធីសាស្រ្តនេះគ្រូគឺជាធនធានដ៏សំខាន់នៅក្នុងថ្នាក់ ចំណែកសិស្សចាំទទួលយកនៅអ្វីដែលគ្រូដាក់ឱ្យ(គ្រូមជ្ឈមណ្ឌល) ហើយអាចសួរគ្រូបាន នៅពេលដែលពួកគេមិនយល់តែប៉ុណ្ណោះ (Natsir, 2014)។ តាមលោក Natsir, (2014) ដដែលបានលើកឡើងថា ការបង្រៀនភាសាមានជំនាញបួនសំខាន់គឺ ជំនាញអាន ជំនាញស្តាប់ ជំនាញនិយាយ និងជំនាញសរសេរ។ ក្នុងវិធីសាស្រ្ត (GTM) បង្រៀនសង្កត់ធ្ងន់ទៅលើតែពីរជំនាញប៉ុណ្ណោះគឺ ជំនាញអាន និងជំនាញសរសេរដែលជំនាញទាំងពីរនេះធ្វើឱ្យសិស្សផ្តោតអារម្មណ៍ទៅលើតែពាក្យ និងវេយ្យាករណ៍ដោយមិនផ្តោតទៅលើអ្វីផ្សេងនោះទេ ពោលគឺបង្រៀនសិស្សឱ្យចេះពីក្បួនច្បាប់នៃភាសាទីពីរហើយយកទៅអនុវត្តក្នុងជីវភាពប្រចាំថ្ងៃរបស់ខ្លួន។ រហូតមកដល់ពេលនេះវិធីសាស្រ្តមួយនេះគឺមិនឆ្លើយតប

ទៅនិងបរិបទសង្គមទេ។ ដូច្នេះវិធីសាស្ត្រ (GTM) ជាវិធីមួយដែលមិនសមស្របសម្រាប់ការបង្រៀន និងរៀនទីពីរនោះទេ ទោះបីជាគ្រូបានបង្ហាញពីកំហុសរបស់សិស្ស ហើយកែនូវរាល់កំហុសទាំងនោះក៏ដោយតែវាអាចជះឥទ្ធិពលដល់សិស្សធ្វើឱ្យពួកគេបាត់បង់នូវសេចក្ដីទុកចិត្ត ហើយមិនហ៊ានប្រើប្រាស់ភាសា (Mart, 2013)។ តាមលោក Brown, (2000) បានបង្ហាញពីចរិកលក្ខណៈរបស់ (GTM) ដូចខាងក្រោមៈ

១. សិស្សទាំងអស់ត្រូវបានគេបង្រៀនជាភាសាទីមួយ (L1)

២.ពាក្យថ្មីជាច្រើនត្រូវបានបង្រៀនក្នុងពេលតែមួយ និងជាពាក្យដាច់ពីគ្នាដោយមិនបានដាក់ជាឧទាហរណ៍ដើម្បីជួយឱ្យសិស្សចងចាំនិងចេះប្រើប្រាស់ពាក្យ ឃ្លាទាំងនោះ ឬជំរុញឱ្យសិស្សធ្វើដោយខ្លួនឯងនោះទេ

៣. ប្រើពេលវេលាច្រើនក្នុងការពន្យល់វេយ្យាករណ៍

៤. ក្បួនច្បាប់វេយ្យាករណ៍ត្រូវបានគេផ្ដល់ឱ្យដោយគ្រាន់តែដាក់ពាក្យចូលគ្នា

៥. ការអានអត្ថបទពិបាកចាប់ផ្ដើមមុនការរៀន

៦. មានការផ្ដោតការយកចិត្តទុកដាក់តិចតួចទៅលើខ្លឹមសារនៃអត្ថបទ តែផ្ដោតទៅលើការវិភាគវេយ្យាករណ៍ច្រើន

៧. ហ្វឹកហាត់ទៅលើលំហាត់ក្នុងការបកប្រែប្រយោគដែលមិនទាក់ទងគ្នាពីខ្លឹមសារមេរៀនទៅជាភាសាទីមួយ

៨. មិនផ្ដោត ឬផ្ដោតអារម្មណ៍តិចតួចទៅលើការបញ្ចេញសម្លេង

វិធីសាស្ត្រ (GTM) មិនអាចជួយសិស្សឱ្យប្រសើរឡើងក្នុងការប្រើប្រាស់ភាសាក្នុងការទំនាក់ទំនងទេ (Brown, 2000)។ មូលហេតុដែល (GTM) នៅតែមានគេយកមកប្រើដោយសារតែការធ្វើតេស្តវេយ្យាករណ៍ និងការបកប្រែងាយស្រួលក្នុងការបង្កើត និងងាយស្រួលក្នុងការដាក់ពិន្ទុវាយតម្លៃការសិក្សារបស់សិស្សផងដែរ។

## ២.៣. វិធីសាស្រ្តបង្រៀនភាសាដោយចាក់សម្លេង ( The Audio Lingual Method )

លោក Brown, (2000)បានបង្ហាញពីគោលការមួយចំនួនដែលទាក់ទងទៅនឹងវិធីសាស្រ្ត (ALM) ដូចខាងក្រោម៖

១. ខ្លឹមសារថ្មីៗត្រូវបានបង្ហាញនៅក្នុងទម្រង់សន្ទនា

២. វាផ្តោតទៅលើការចងចាំប្រយោគ

៣. សំណង់ឃ្លាមានទំនាក់ទំនងគ្នាជាមួយខ្លឹមសារនៃការវិភាគផ្សេងៗ ត្រូវបានបង្រៀនក្នុងពេលតែមួយ

៤. សំណង់ឃ្លាសំខាន់ត្រូវបានបង្រៀនតាមរយៈការហ្វឹកហាត់ថាតាម

៥. គ្មាន ឬមានការពន្យល់វេយ្យករណ៍តិចទួច ហើយវេយ្យករណ៍ត្រូវបានពន្យល់រួចបង្កើតជាទ្រឹស្តី

៦. ពាក្យថ្មីស្រង់យកពីអត្ថបទតែមួយគត់

៧. ប្រើប្រាស់កាសែតសម្រាប់ស្តាប់

៨. ផ្តោតសំខាន់ទៅលើការបញ្ចេញសម្លេង

៩. ប្រើប្រាស់ភាសាកំណើតតិចបំផុតទាល់តែគ្រូអនុញ្ញាត

១០. ចម្លើយជោគជ័យត្រូវបានអនុវត្តភ្លាមៗ

១១.មានការខិតខំប្រឹងប្រែងដើម្បីឱ្យសិស្សប្រើប្រាស់ការបញ្ចេញសម្លេងដោយគ្មានកំហុស

១២. មាននិន្នាការទាញយកផលប្រយោជន៍ពីភាសាហើយខ្វល់ពីខ្លឹមសារ

នៅក្នុងវិធីសាស្រ្ត (ALM) ផ្តោតទៅលើឃ្លាជាជាងខ្លឹមសារមេរៀន មិនត្រឹមតែប៉ុណ្ណោះវាត្រូវការចងចាំឃ្លាសំខាន់ផ្អែកលើការសន្ទនាដែរ។

## ២.៤. វិធីសាស្រ្តបង្រៀនភាសាដោយចាក់ភ្លេង ( Suggestopedia )

Suggestopedia គឺជាវិធីសាស្រ្តមួយដែលផ្តោតទៅលើទំនាក់ទំនងរវាងសក្តានុពលផ្នែកខួរក្បាល និងសមត្ថភាពនៃការរៀនដែលវាមានលក្ខណៈសមស្របសម្រាប់ការបង្រៀន

និយាយសម្រាប់អ្នកសិក្សាវ័យក្មេង(Apriana & Islamiyah, 2011)។ Suggestopedia ត្រូវបានបង្កើតឡើងដោយលោក Lazanov ក្នុងឆ្នាំ១៩៧៥ដែលលោកជាចិត្តវិទូជនជាតិប៊ុលហ្គារីម្នាក់។ ការសិក្សាអាចទទួលបានច្រើនជាងអ្វីដែលយើងគិត និងផ្តល់ឱ្យទៅទៀតប្រសិនបើអ្នកសិក្សាប្រើប្រាស់ថាមពលខួរក្បាល និងសមត្ថភាពផ្នែកខាងក្នុងរបស់ខ្លួន។ ខួរក្បាលអាចដំណើរការទៅបានយ៉ាងល្អ ប្រសិនបើវាត្រូវបានគេផ្តល់ឱ្យនៅលក្ខខណ្ឌត្រឹមត្រូវសម្រាប់ការសិក្សានៅក្នុងស្ថានភាពដូចជាលក្ខណៈសម្រាក។ សិស្សភាគច្រើនប្រើប្រាស់សមត្ថភាពខួរក្បាលរបស់ពួកគេពីប្រាំទៅដប់ភាគរយតែប៉ុណ្ណោះ (Apriana & Islamiyah, 2011)។ គោលបំណងដ៏សំខាន់របស់ Suggestopedia គឺការលើកទឹកចិត្តក្នុងការប្រើប្រាស់សក្តានុពលខួរក្បាលដើម្បីរៀននូវអ្វីដែលទទួលបានពីការធ្វើសំណើរ។ អ្នកសិក្សាដែលមានភាពលំបាកក្នុងការរៀនភាសាអង់គ្លេសដែលជាភាសាទីពីរនោះគឺ ដោយសារតែភាពភ័យខ្លាចរបស់ពួកគេនៅក្នុងការធ្វើឱ្យមានកំហុសផ្សេងៗ។ អ្នកសិក្សាក្នុងស្ថានភាពបែបនេះគឺបេះដូង និងឈាមរបស់គេកើនឡើងដោយសារតែភាពភ័យខ្លាចជាអ្នករាំខ្ទប់នូវព័ត៌មានផ្សេងៗ (Apriana & Islamiyah, 2011)។ ខាងក្រោមនេះគឺជាលក្ខណៈមួយចំនួននៃ Suggestopedia៖

១. បរិស្ថានប្រកបដោយផាសុកភាព

ការរៀបចំថ្នាក់រៀនគឺមិនដូចជាការរៀបចំថ្នាក់រៀននៃវិធីសាស្រ្តដទៃទេ គឺកៅអីត្រូវបានរៀបចំជាពាក់កណ្តាលរង្វង់ដែលបែរមុខទៅរកក្តារខៀន ដើម្បីធ្វើឱ្យសិស្សផ្តោតការយកចិត្តទុកដាក់និងសម្រាកជាង។ បន្ថែមលើនេះទៅទៀត ពន្លឺនៅក្នុងបន្ទប់ត្រូវរៀបចំឱ្យមានភាពស្រទន់ដើម្បីឱ្យសិស្សសម្រាកខួរក្បាលរបស់ពួកគេ។

២. ការប្រើប្រាស់តន្ត្រី

ការប្រើប្រាស់តន្ត្រីនៅក្នុងវិធីសាស្រ្តនេះគឺតន្ត្រី Baroque ក្នុងដំណើរការរៀន។ តន្ត្រីនេះមានកម្លាំង ៦០ក្នុងមួយវិនាទីហើយមានគុងច្បាស់លាស់ដែលបង្កើតនូវប្រភេទនៃសភាពការសម្រាកបានច្រើនជាអតិបរិមា។ តន្ត្រី Baroque អាចជួយឱ្យសិស្សសម្រាកដែលធ្វើការឱ្យការទទួលយកមានការកើនឡើងកាត់បន្ថយកម្រិតនៃសម្ពាធឈាម និងចង្វាក់បេះដូង។

៣. ការរៀនសើរៗខាងក្រៅ

សិស្សរៀនភាសាអង់គ្លេសមិនត្រឹមតែតាមរយៈការណែនាំផ្ទាល់នោះទេគឺ ថែមទាំងការរៀនផ្នែកខាងក្នុងនោះដែរ។ វាលើកទឹកចិត្តតាមរយៈការបង្ហាញនៅក្នុងបរិយាកាសរៀននៃការប្រើប្រាស់ ផ្ទាំងក្រដាសធំ ការតុបតែងអ្វីដែលទាក់ទងទៅនឹងខ្លឹមសារមេរៀន ព័ត៌មានទាក់ទងនឹងវេយ្យករណ៍ផ្សេងៗដែលត្រូវបានគេផ្លាស់ប្តូរជារៀងរាល់ថ្ងៃ។ តាមរបៀបនេះសិស្សអាចរៀនអ្វីៗទាំងអស់ដោយប្រយោលទាំងនៅក្នុងថ្នាក់រៀននិងនៅក្រៅថ្នាក់រៀន។

៤. មិនផ្តោតលើកំហុស

ក្នុងដំណើរការរៀនរបៀបនេះគឺសិស្សដែលបង្កើតនូវកំហុសត្រូវបានគេលើកលែង។

៥. កិច្ចការផ្ទះមានកំណត់

សិស្សអានអត្ថបទដែលគ្រូផ្តល់ឱ្យនៅក្នុងថ្នាក់រៀន នៅផ្ទះមុនពេលចូលសម្រាកហើយអានម្តងទៀតនៅពេលព្រឹកក្រោកពីដំណេក។

៦. តន្ត្រី ល្ខោន សិល្បៈត្រូវបានគេដាក់បញ្ចូលនៅក្នុងដំណើរការរៀននេះផងដែរ (Apriana & Islamiyah, 2011)។

គុណសម្បត្តិរបស់ Suggestopedia

១. វិធីសាស្ត្រនេះអាចធ្វើនៅក្នុងថ្នាក់ធម្មតាជាមួយកៅអីដែលមានផាសុកភាពដែលការហ្វឹកហាត់អាចជួយឱ្យសិស្សសម្រាកផ្នែកអារម្មណ៍។

២. សិស្សចងចាំបានល្អនិងមានភាពរលូនពីព័ត៌មានមកពីគ្រូ

៣. សិស្សអាចចង់បានពីការណែនាំនៃការបង្រៀនទាំងការណែនាំផ្ទាល់និងការណែនាំមិនផ្ទាល់និងបរិស្ថាននៃការរៀនកើតឡើង។

៤. សិស្សប្រើប្រាស់ភាសាដោយឯករាជ្យ មានទំនួលខុសត្រូវជាលក្ខណៈបុគ្គលសម្រាប់ការរៀនផ្ទាល់ និងមានទំនុកចិត្តជាង (Apriana & Islamiyah, 2011)។

គុណវិបត្តិរបស់ Suggestopedia

១. បញ្ហាមួយក្នុងចំណោមបញ្ហាជាច្រើនដែលវិធីសាស្ត្រនេះជួបប្រទះនោះគឺដោយសាប្រទេសកំពុងអភិវឌ្ឍមួយចំនួន មានថ្នាក់ដែលមានសិស្សច្រើនដែលថ្នាក់ទាំងនោះមានសិស្សចាប់ពី ៣០ ទៅ ៤០ នាក់ក្នុងមួយថ្នាក់ដែលជាទូទៅសិស្សគួរតែមានត្រឹមតែ ១២នាក់ប៉ុណ្ណោះក្នុងមួយថ្នាក់។

២. មនុស្សមួយចំនួនបានលើកឡើងថាវិធីសាស្ត្រនេះបានប្រើប្រាស់ភាពត្រូវសណ្តំដូចនេះវាជះឥទ្ធិពលដល់មនុស្ស។

៣. វិធីសាស្ត្រនេះត្រូវការស្ថានភាពថ្នាក់ប្រៀបបីដូចជាស្ថានភាពក្មេងដូចនេះសិស្សមួយចំនួនដែលមិនចូលចិត្តស្ថានភាពនេះដោយពួកគេគិតថាពួកគេពេញវ័យហើយ (Apriana & Islamiyah, 2011)។

វិធីសាស្ត្រនេះមានភាពខុសគ្នាទាំងស្រុងពី វិធីសាស្ត្របង្រៀនភាសាបរទេសដទៃទៀត (Lozanow, 2005)។ Suggestopedia គ្រូត្រូវជ្រើសរើសអត្ថបទមួយដែលមានលក្ខណៈងាយស្រួលក្នុងការចងចាំ។ បន្ទាប់មកគ្រូអានអត្ថបទនោះឱ្យសិស្សស្តាប់តាមល្បឿនធម្មតាព្រមជាមួយនឹងការលើកដាក់សម្លេងផងដែរ ព្រមគ្នាជាមួយសិស្សស្តាប់ដោយយកចិត្តទុកដាក់។ នៅពេលជួបនឹងពាក្យពិបាក គ្រូត្រូវថាពាក្យដដែលនោះចំនួនបីដង ដែលជឿជាក់ថាការថាពាក្យនេះច្រើនដងនឹងជួយឱ្យសិស្សមានការចងចាំបានយូរ (Lozanow, 2005)។ គ្រូចាក់ភ្លេងហើយអានអត្ថបទឱ្យសិស្សស្តាប់ស្របពេលជាមួយគ្នានេះដែរ។ គ្រូចាក់ភ្លេងឱ្យសិស្សអានអត្ថបទតាមភ្លេងនោះរហូតដល់ពួកគេចងចាំអត្ថបទនេះទាំងមូល។ វិធីសាស្ត្រនេះបង្រៀនឱ្យសិស្សចងចាំអត្ថបទដែលបានរៀនរួច ហើយពួកគេចេញទៅផ្ទះដោយមិនបានប្រាប់ឱ្យធ្វើអ្វីទាំងអស់ដូចជាកិច្ចការផ្ទះជាដើម (Brown, 2000)។

### ២.៥. វិធីសាស្ត្របង្រៀនភាសាឱ្យរាងកាយទទួល ( Total Physical Response )

វិធីសាស្ត្រ TPR គឺជាវិធីសាស្ត្រមួយក្នុងការបង្រៀនភាសាទីពីរដោយផ្អែកលើការស្តាប់និងផ្សាភ្ជាប់ទៅនឹងសកម្មភាពរាងកាយដែលត្រូវបានរៀបចំឡើង ដើម្បីពង្រឹងការយល់ដឹង

សម្រាប់វត្ថុមូលដ្ឋានជាក់លាក់មួយ (Asher, 1968)។ វិធីសាស្ត្រនេះគឺឱ្យសិស្សស្តាប់តាមការបញ្ជាជាភាសាទីពីរហើយធ្វើតាមនូវអ្វីដែលគេបញ្ជានោះ ដោយប្រើសកម្មភាពរាងកាយ របស់ខ្លួន។ តែទោះបីជាយ៉ាងណាក៏ដោយ TPR ក៏នៅតែមានគុណសម្បត្តិ និងគុណវិបត្តិរបស់ខ្លួនដែរ។ ចំពោះគុណសម្បត្តិមានដូចជាវាមានលក្ខណៈងាយស្រួលនិងធ្វើឱ្យមានលក្ខណៈសប្បាយសម្រាប់សិស្សនិងគ្រូ ដែលធ្វើឱ្យសិស្សបន្ធូរភាពតានតឹងផ្នែកអារម្មណ៍ជាចំណុចសំខាន់ក្នុងការរៀនភាសា។ TPR បានដាក់បញ្ចូលគ្នានូវរបៀបរៀនទាំងការស្តាប់ និងការប្រើប្រាស់កាយវិការរបស់ខ្លួននៅពេលដែលកំពុងស្តាប់។ មិនត្រឹមតែប៉ុណ្ណោះទេ TPR គឺជាឧបករណ៍យ៉ាងល្អមួយសម្រាប់ការបង្កើនសមត្ថភាពវាក្យស័ព្ទ ហើយអាចរក្សាទុកបានរយៈពេលយូរ។ ម្យ៉ាងវិញទៀត TPR មិនត្រូវការពេលវេលាយូរសម្រាប់ការរៀបចំផ្សេងៗសម្រាប់ការបង្រៀននោះទេ ហើយវាមានប្រសិទ្ធភាពបំផុតសម្រាប់មនុស្សវ័យជំទង់ និងអ្នកសិក្សាវ័យក្មេងផងដែរ។ តែទោះបីជាយ៉ាងនេះក្តី TPR នៅតែមានគុណវិបត្តិមួយចំនួនផងដែរ ដូចជាភាពប្រឈមសម្រាប់អ្នកសិក្សាដែលមានចរឹតខ្មាសអៀនច្រើននៅក្នុងការធ្វើកាយវិការតាមការបញ្ជាផងដែរ។ TPR មិនបានផ្តល់ឱកាសគ្រប់គ្រាន់សម្រាប់អ្នកសិក្សា ដើម្បីនិយាយនូវអ្វីដែលអ្នកសិក្សាបានបង្កើតឡើងនោះទេគឺគ្រាន់តែស្តាប់និងធ្វើកាយវិការតាមខ្លឹមសារដែលបានរៀនប៉ុណ្ណោះ។ TPR ជាវិធីសាស្ត្រមួយដែលតម្រូវឱ្យអ្នកសិក្សាធ្វើសកម្មភាពដដែលៗច្រើនដងពេកដែលជាហេតុធ្វើឱ្យអ្នកសិក្សាមានការធុញទ្រាន់ក្នុងការរៀន។ ការរៀបចំវិធីសាស្ត្របង្រៀនតាមបែប TPR គឺក្លាយទៅជាបញ្ហាសម្រាប់ការអប់រំកម្រិតខ្ពស់ព្រោះពួកគេមានវ័យច្រើន និងមានភាពអៀនខ្មាសច្រើនផងដែរ ។ លោក Asher, (1968) បានបន្ថែមថា ដើម្បីឱ្យ TPR ទទួលបានជោគជ័យក្នុងការបង្រៀន គឺត្រូវប្រើប្រាស់ជាមួយនឹងវិធីសាស្ត្រនិងគោលវិធីដទៃផ្សេងទៀត។

### ២.៦. **ការបង្រៀនភាសាបែបទំនាក់ទំនង** ( Communicative Language Teaching )

វិធីសាស្ត្រនេះមានប្រជាប្រិយភាពបំផុតក្នុងចំណោមវិធីសាស្ត្រដទៃទៀត។ វាត្រូវបានគេប្រើប្រាស់យ៉ាងពេញនិយមសម្រាប់ការបង្រៀន និងរៀនភាសានាពេលបច្ចុប្បន្ននេះ។ វិធី

សាស្ត្រនេះមានលក្ខណៈខុសគ្នាពីវិធីសាស្ត្របកប្រែ (GTM) ត្រង់ថាវាជួយឱ្យសិស្សចេះប្រើប្រាស់ភាសាក្នុងការទំនាក់ទំនងជាជាងការវិភាគភាសា (Natsir, 2014)។ នៅក្នុងការបង្រៀនតាមបែប CLT ទោះបីគ្រូបង្រៀនខ្លឹមសារមេរៀនតាមភាសាកំណើតមែនតែក្នុងការទំនាក់ទំនងគេមិនអនុញ្ញាតឱ្យប្រើភាសាកំណើតនោះទេ។ ម្យ៉ាងវិញទៀតការបង្រៀនពាក្យថ្មីគ្រូព្យាយាមទាញពាក្យតាមរយៈការពន្យល់ឱ្យសិស្សប្រាប់នូវអ្វីដែលពួកគេដឹងដោយខ្លួនឯង។ ចំពោះការបង្រៀនវេយ្យករណ៍វិញ ទោះបីការបង្រៀនដោយប្រើប្រាស់ភាសាទីមួយពិតមែនតែគ្រូនៅតែព្យាយាមពន្យល់ ហើយទាញអារម្មណ៍សិស្សទៅរកខ្លឹមសារមេរៀននៅក្នុងអត្ថបទវិញ។ ការបង្រៀនរបៀបនេះគឺ ធ្វើឱ្យសិស្សគ្មានភាពខ្មាស់អៀននៅក្នុងការប្រើប្រាស់ភាសានៅក្នុងការទំនាក់ទំនងតាមរយៈអ្វីដែលពួកគេបានរៀន ឬបានស្គាល់នោះទេ។ ប៉ុន្តែទោះបីជាយ៉ាងនេះក្តីកំហុសប្រាកដជាកើតមានឡើងទៅលើផ្នែកវេយ្យាករណ៍ប្រសិនបើ គ្រូមិនយកចិត្តទុកដាក់កែវានៅចុងបញ្ចប់នៃមេរៀនទេនោះ (Natsir, 2014)។ ជាមួយគ្នានេះដែរ ចំពោះការប្រើប្រាស់សម្ភារៈបង្រៀនវិញ គ្រូប្រើប្រាស់សម្ភារៈដែលសិស្សស្គាល់នៅក្នុងជីវភាពប្រចាំថ្ងៃរបស់ពួកគេដែលជាហេតុធ្វើឱ្យយល់មេរៀនកាន់តែច្បាស់។ ក្នុងវិធីសាស្ត្រ CLT គឺបង្រៀនសិស្សឱ្យចេះប្រើប្រាស់ភាសាដែលពួកគេកំពុងរៀនក្នុងសកម្មភាពប្រចាំថ្ងៃរបស់ពួកគេ។ ក្នុងវិធីសាស្ត្រនេះគ្រូនិងសិស្សមានការទំនាក់ទំនងគ្នាយ៉ាងសកម្ម មិនតែប៉ុណ្ណោះទេ ការទំនាក់ទំនងរវាងសិស្សនិងសិស្សក៏សកម្មដែរ។ គ្រូមិនមែនធនធានតែមួយគត់ទេតែជាអ្នកសម្របសម្រួលនៅក្នុងថ្នាក់ទៀតផង (Natsir, 2014)។ វិធីសាស្ត្រ CLT បង្រៀនទាំងបួនជំនាញ គឺជំនាញអាន ជំនាញស្តាប់ ជំនាញសរសេរ និងជំនាញនិយាយ ដែលជំនាញទាំងបួននេះបានទទួលនៅពេលដែលពួកគេចាប់ផ្តើមពិភាក្សាគ្នាជាក្រុម ឬនៅពេលដែលពួកគេរៀននៅក្នុងថ្នាក់។ ដូច្នេះសកម្មភាពទាំងនេះមានលក្ខណៈល្អប្រសើរណាស់សម្រាប់ដំណើរការបង្រៀន និងរៀន (Natsir, 2014)។

## ២.៧.វិធីសាស្ត្ររៀនភាសាតាមបែបសហគមន៍ ( Community Language Learning )

វិធីសាស្ត្រការរៀនភាសាតាមបែបសហគមន៍ (CLL) ត្រូវបានបង្កើតឡើងដោយលោក Charles Curran និងជំនួយការរបស់លោក។ លោក Curran មានឯកទេសខាងប្រឹក្សាយោបល់ និងជាសាស្ត្រាចារ្យចិត្តវិទ្យានៅក្នុងសាកលវិទ្យាល័យឡូយ៉ូឡាក្នុងរដ្ឋឈីហ្គាហ្គោ (Richards & Rodgers, 2002)។ ការរៀនភាសាបែបសហគមន៍ តំណាងឱ្យវិធីសាស្ត្ររៀនតាមបែបប្រឹក្សាយោបល់ដើម្បីបង្រៀនភាសា។ គ្រូមិនត្រឹមជាអ្នកផ្ទេរចំណេះដឹងប៉ុណ្ណោះទេថែមទាំងជាអ្នកជំនាញក្នុងការដោះស្រាយបញ្ហាផ្សេងៗ ដែលអ្នកសិក្សាកំពុងជួបប្រទះក្នុងការរៀនអ្វីដែលថ្មី។ ក្នុងការរៀនបែបសហគមន៍ គឺការរៀនដែលទទួលបានជោគជ័យកើតឡើងនៅពេលដែលការយល់ពីមនោសញ្ចេតនារវាងអ្នកសិក្សានិងគ្រូត្រូវបានបង្កើតឡើងដើម្បីជំរុញការរៀនសូត្រគ្មានកំណត់។ លក្ខណៈពិសេសរបស់វិធីសាស្ត្រនេះគឺកាត់បន្ថយការថប់អារម្មណ៍ និងការយកឈ្នះរបាំងនៃការរៀនដែលអ្នកសិក្សាជួបប្រទះក្នុងជំហានដំបូងនៃដំណើរការរៀន (Richards & Rodgers, 2002)។ ខាងក្រោមនេះគឺជាគោលការណ៍សំខាន់ៗមួយចំនួនដែលនឹងបម្រើឱ្យវិធីសាស្ត្រនៃការរៀនភាសាតាមបែបសហគមន៍៖

១. ការបង្កើតនូវមនោសញ្ចេតនាផ្នែកអារម្មណ៍រវាងគ្រូនិងអ្នកសិក្សាក្នុងគោលបំណងបង្កើតបរិស្ថាននៃការរៀនដោយសុវត្ថិភាព។ ធ្វើដូចនេះសិស្សមានបំណងរៀនមានប្រសិទ្ធិភាពជាងនៅពេលដែលពួកគេមានអារម្មណ៍ថាសុវត្ថិភាព។

២. ដោយសារតែភាសាគឺសម្រាប់ការទំនាក់ទំនង ដូចនេះសិស្សគួរតែត្រូវបានលើកទឹកចិត្តនៅក្នុងការទំនាក់ទំនងជាប្រចាំតាមដែលអាចធ្វើទៅបានក្នុងអំឡុងពេលរៀន។

៣. គ្រូឈរពីក្រោយសិស្សក្នុងគោលបំណងសម្របសម្រួលក្នុងដំណើរការរៀនរបស់សិស្ស។

៤. គ្រូត្រូវគោរពពកម្រិតទំនុកចិត្តរបស់អ្នកសិក្សា និងការផ្ទេរឱ្យពួកគេវិញនូវអ្វីដែលត្រូវការធ្វើដើម្បីជោគជ័យ។

៥. អ្នកសិក្សាចង់ដឹងពីដែនកំណត់នៃកម្មភាពបង្រៀនរបស់គ្រូដូចនេះធ្វើឱ្យពួកគេមានអារម្មណ៍សុវត្ថិភាព។

៦. គ្រូនិងអ្នកសិក្សាគឺ ជាមនុស្សតែមួយដែលពួកគេត្រូវចែករំលែកបទពិសោធគ្នាទៅវិញទៅមក។

៧. គ្រូចាត់ទុកអ្នកសិក្សាជាមនុស្សសំខាន់ ដូចនេះគ្រូតែងតែស្តាប់ពួកគេដោយមិនចាំបាច់ផ្តល់យោបល់ផ្សេងៗដើម្បីយល់ពីអារម្មណ៍អំពីដំណើរការរៀន។

៨. អ្នកសិក្សាប្រើភាសាកំណើតរបស់ខ្លួន ដើម្បីយល់ពីខ្លឹមសារហើយបង្កើតពីអ្វីដែលដឹងទៅអ្វីដែលមិនដឹងពេលពួកគេយល់ពីអន្តរកម្មក្នុងថ្នាក់ក្នុងការសម្របសម្រួលការរៀន។

៩. អ្នកសិក្សាតម្រូវឱ្យចូលរួមកិច្ចការមួយក្នុងមួយពេល ហើយត្រូវបានផ្តល់ឱ្យនូវពេលវេលាធ្វើការឆ្លុះបញ្ចាំងក្នុងគោលបំណងនៃការរៀន។

១០. អ្នកសិក្សាមានជម្រើសនៅអ្វីដែលពួកគេចង់ហ្វឹកហាត់ ដើម្បីធ្វើឱ្យមានការរីកចម្រើន។

១១. អ្នកសិក្សាធ្វើការជាក្រុមដើម្បីឱ្យមានស្មារតីសហាគមន៍ ដូចនេះពួកគេអាចរៀនពីគ្នាទៅវិញទៅមកព្រមទាំងជាមួយគ្រូហើយការសហការណ៍គ្នាត្រូវបានលើកទឹកចិត្តជាជាងការប្រគួតប្រជែងគ្នា។

១២. គ្រូកែនូវកំហុសរបស់សិស្សដែលពួកគេបានបង្កើតឡើងតាមវិធីត្រជាក់។

១៣. ដោយការអានឃ្លារបស់ពួកគេទៅកាន់សិស្សដទៃទៀត អ្នកសិក្សាអាចអភិវឌ្ឍនូវស្មារតីសហាគមន៍និងបង្កើតនូវសេចក្តីទុកចិត្តដែលអាចជួយពួកគេកាត់បន្ថយការគំរាមកំហែងក្នុងស្ថានភាពរៀនថ្មី។

១៤. ក្រៅពីភាសា អ្នកសិក្សាអាចឆ្លុះបញ្ចាំងនូវបទពិសោធដូចនេះពួកគេមានឱកាសក្នុងការរៀនភាសា ការរៀនរបស់ពួកគេផ្ទាល់ និងរបៀបនៃការៀនពីគ្នាទៅវិញទៅមកនៅក្នុងសហាគមន៍។

១៥.កម្មវិធីសិក្សាត្រូវបានបង្កើតឡើងដោយសិស្សក្នុងដំណាក់កាលដំបូងដូចនេះសិស្សមានឆន្ទៈរៀននូវអ្វីដែលពួកគេបង្កើតដោយខ្លួនឯង (Larsen-Freeman & Anderson, 2011)។

នៅក្នុងការរៀនភាសាបែបសហគមន៍គឺ សិស្សមិនត្រឹមតែប្រើប្រាស់ខ្លឹមសារក្នុងការទំនាក់ទំនងទេថែមទាំងរៀនទទួលខុសត្រូវក្នុងការរៀនរបស់ពួកគេ (Richards & Rodgers, 2002)។

តាមវិធីសាស្ត្ររៀនភាសាបែបសហគមន៍ មិនចាំបាច់មានសៀវភៅសិក្សាគោល ការរៀបចំគម្រោងមេរៀន ដោយគ្រាន់តែអង្គុយជារង្វង់មូលមិនលើសពីដប់ពីរនាក់ (Larsen-Freeman & Anderson, 2011)។ ពួកគេផ្ទាល់ភាគច្រើនជាអ្នកបង្កើតការទំនាក់ទំនងគ្នាផ្ទាល់មាត់ដោយប្រើប្រាស់ភាសាកំណើតឬខ្លឹមសារមេរៀន គ្រូអាចជួយបកប្រែពីភាសាទីមួយទៅភាសាទីពីរផងដែរ (Blair, 1991)។

វិធីសាស្ត្រនេះគ្រូជ្រើសរើសប្រធានបទមួយឱ្យសិស្សពិភាក្សាគ្នាជាគូឬជាក្រុមតាមរយៈការសន្ទនាគ្នាហើយបន្ទាប់មក គ្រូហៅពាក្យដែលពួកគេជួបប្រទះនៅក្នុងការសន្ទនាគ្នានោះដាក់លើក្ដារខៀន។ គ្រូឱ្យសិស្សស្ម័គ្រចិត្តអានពាក្យដែលពួកគេគឺមិនច្បាស់ក្នុងការបញ្ចេញសម្លេងឱ្យមិត្តរួមថ្នាក់ស្ដាប់ដោយគ្រូជាអ្នកថាតាមរហូតដល់សិស្សជឿថា ការបញ្ចេញសម្លេងរបស់ពួកគឺត្រឹមត្រូវ។ ក្នុងដំណាក់កាលនេះគ្រូប្រៀបដូចជាកុំព្យូទ័រដែលគ្រូមិនអាចបញ្ឈប់បានទេដរាបណាសិស្សមិនបញ្ឈប់ដោយខ្លួនឯងនេះ។ ត្រង់ចំណុចនេះបើសិស្សមិនឈប់អានពាក្យទាំងនោះទេគ្រូក៏មិនឈប់ដែរ។ វិធីសាស្ត្រនេះអាចជួយឱ្យសិស្សរៀននូវពាក្យថ្មីៗ របៀបបញ្ចេញសម្លេងរបស់ពាក្យនីមួយៗ និងការប្រើប្រាស់ពាក្យទាំងនោះនៅក្នុងសហគមន៍។ នៅចុងបញ្ចប់នៃមេរៀន គ្រូដាក់កិច្ចការផ្ទះដោយការសរសេរឱ្យសិស្សធ្វើដោយប្រើប្រាស់ពាក្យដែលរៀនរួចនោះ ហើយសួរសិស្សពីអារម្មណ៍របស់ពួកគេនៅក្នុងដំណើរការរៀនរហូតដល់ពួកគេមានអារម្មណ៍ថាធូរស្រាលជាងមុន (Richards & Rodger, 2002)។

ដោយសារតែវិធីសាស្ត្ររៀនតាមបែបសហគមន៍គឺផ្តោតទៅលើការសន្ទនា និងការបញ្ចេញសម្លេងដូចនេះ សិស្សជាអ្នករើសខ្លឹមសារដោយខ្លួនឯងហើយចំណុចវេយ្យាករណ៍មួយចំនួនគឺតាមតែសិស្សប្រើប្រាស់ប៉ុណ្ណោះ។

ការរៀនតាមវិធីសាស្ត្រនេះគឺគ្មានទម្រង់បែបបទវាយតម្លៃផ្លូវការតាមការសរសេរ ឬតាមការប្រឡងផ្ទាល់មាត់នោះទេដរាបណាសាលាជាអ្នកតម្រូវឱ្យធ្វើតែប៉ុណ្ណោះ។

ទោះបីវិធីសាស្ត្របង្រៀនភាសាបែបសហគមន៍មានអត្ថប្រយោជន៍ជាច្រើនក៏ដោយ ក៏វានៅមានចំណុចខ្សោយមួយចំនួនដែរដូចជានៅពេលដែល CLL ទទួលបានជោគជ័យគឺវាអាស្រ័យដោយគ្រូដែលជាទីប្រឹក្សានៅគ្រប់ជំហានទាំងអស់ (Brown, 1997)។ គ្រូត្រូវតែចេះច្បាស់ទាំងវប្បធម៌ និងភាសាវិទ្យាក្នុងភាសាទីពីរនិងភាសាកំណើតរបស់សិស្សដើម្បីបកប្រែប្រយោគផ្សេងៗដើម្បីឱ្យយល់ក្នុងពេលធ្វើការឆ្លុះបញ្ចាំង។ ម្យ៉ាងវិញទៀត វិធីសាស្ត្រនេះមិនអាចប្រើបានជាមួយនឹងសិស្សដែលមានចំនួនច្រើននោះទេ វាអាចមានបញ្ហាជាមួយនឹងសិស្សដែលមានវ័យក្មេងៗដែលជាទូទៅប្រើប្រាស់សៀវភៅសិក្សាគោលនៅក្នុងថ្នាក់រៀន។ ជាចុងក្រោយវិធីសាស្ត្រនេះមិនមានការប្រើប្រាស់វេយ្យាករណ៍ពេញលេញនោះទេ គឺវាអាស្រ័យទៅលើសិស្សជាអ្នកប្រើប្រាស់ភាសាតែប៉ុណ្ណោះ។

វិធីសាស្ត្រ CLL ហាក់ដូចជាមិនពេញចិត្តចំពោះគ្រូមួយចំនួនដែលបង្រៀនភាសាបរទេសនោះទេ។ តែទោះបីជាយ៉ាងនេះក្តីពួកគេក៏អាចដកស្រង់នៅសកម្មភាពមួយចំនួនមកបង្រៀនសិស្សដែរដូចជា ការចាក់សម្លេង ការធ្វើការឆ្លុះបញ្ចាំងពីមេរៀនជាដើម។

### **២.៨.វិធីសាស្ត្របង្រៀនភាសាផ្អែកលើកិច្ចការ**( Task Based Language Teaching )

Prabhu (1987) បានបង្កើតវិធីសាស្ត្រនៃការរៀនដោយផ្តោតទៅលើកិច្ចការក្នុងភាគខាងត្បូងនៃប្រទេសឥណ្ឌា។ លោក Prabhu បានជឿថាអ្នកសិក្សាអាចរៀនតាមវិធីនេះមានប្រសិទ្ធភាពជាងពេលដែលពួកគេផ្តោតការគិតរបស់ពួកគេច្រើនទៅលើកិច្ចការ ជាជាងការផ្តោតទៅលើភាសាដែលពួកគេកំពុងប្រើប្រាស់។

យោងតាមលោក Willis (1996), កិច្ចការអាចត្រូវបានគេកំណត់ថាជាសកម្មភាពដែលខ្លឹមសារមេរៀនត្រូវបានប្រើប្រាស់ដោយអ្នកសិក្សា សម្រាប់គោលបំណងនៃការទំនាក់ទំនងដើម្បីសម្រេចបាននូវលទ្ធផល។ ការរៀនដោយផ្តោតទៅលើកិច្ចការគឺមានភាពខុសគ្នាពីវិធីសាស្ត្រនៃការបង្រៀនភាសា។ វាអាចជួយឱ្យអ្នករៀនភាសាដោយដាក់ខ្លួនពួកគេទៅក្នុងស្ថានភាពជាក់ស្តែង។ ការរៀនដោយផ្តោតទៅលើកិច្ចការមានគុណសម្បត្តិដោយជួយសិស្សឱ្យអាចប្រើប្រាស់ជំនាញរបស់គេទៅតាមកម្រិតខ្លួន។ វាជួយឱ្យការផ្តោតរបស់សិស្សសម្រេចគោលដៅដែលភាសាក្លាយទៅជាឧបករណ៍ និងសារៈសំខាន់នៃការប្រើប្រាស់ភាសា (Willis, 1996).

លោក Willis (1996) បានគាំទ្រគំនិតដែលថា គោលវិធីនៃការរៀនដោយផ្តោតទៅលើកិច្ចការគឺ ជាគោលវិធីសិស្សមជ្ឈមណ្ឌលដែលអ្នកសិក្សាទាំងអស់រៀនខ្លឹមសារមេរៀនតាមរយៈការលើកទឹកចិត្តដោយខ្លួនឯង ផ្តោតលើកិច្ចការ និងក្រុមស្រាវជ្រាវផ្អែកលើគម្រោងកិច្ចការ។ នៅក្នុងការរៀនដោយផ្តោតលើកិច្ចការធ្វើឱ្យការរៀនភាសាប្តូរទៅជាដំណើរការដែលជាប់ទាក់ទង ក្នុងការផ្តល់ឱកាសឱ្យអ្នកសិក្សាចែករំលែកគ្នាតាមរយៈការទំនាក់ទំនងដែលជាខ្លឹមសារសំខាន់មួយ (Skehan, 1996)។ ការរៀនដោយផ្តោតលើកិច្ចការមានឫសគល់ក្នុងការបង្រៀនភាសាតាមបែបទំនាក់ទំនង។ គ្រូមួយចំនួនបានប្រើប្រាស់របៀបការរៀនភាសាដោយការដាក់កិច្ចការតាមរយៈមូលហេតុផ្សេងៗគ្នា។ គ្រូខ្លះបានប្រើកម្មវិធីសិក្សាផ្តោតលើកិច្ចការក្នុងគោលបំណងធ្វើឱ្យភាសាក្នុងថ្នាក់រៀនជាការទំនាក់ទំនាងជាក់លាក់មួយ ជាជាងការប្រាស្រ័យទាក់ទងដែលជាលទ្ធផលពីសកម្មភាពក្នុងថ្នាក់ ដោយគ្មានការផ្សារភ្ជាប់ជាមួយនឹងស្ថានភាពជាក់ស្តែង។

លោក Willis (1996), លោក Prabhu (1987), លោក Nunan (1989) បានលើកឡើងថាក្របខណ្ឌនៃការរៀនផ្តោតលើកិច្ចការមានបីជំហានសំខាន់ៗគឺៈ

### ១. ជំហានមុនការដាក់កិច្ចការ

នៅក្នុងជំហានមុនការដាក់កិច្ចការនេះ អ្នកសិក្សាត្រូវរៀបចំសម្រាប់កិច្ចការបំពេញ។ លោក Willis (1996) បានបង្ហាញថាសកម្មភាពមួយក្នុងចំណោមសកម្មភាពជាច្រើន

នៅក្នុងជំហាននេះគឺណែនាំខ្លឹមសារមេរៀនដល់អ្នកសិក្សា ឬផ្តល់ដល់អ្នកសិក្សាជាមួយជំនួយភាសា។ លោក Willis (1996) បានលើកឡើងថាជំនួយភាសានេះអាចជា វាក្យសព្ទ ឬទម្រង់ផ្សេងៗដែលសំខាន់សម្រាប់ការបំពេញការងារ។ លោកជឿជាក់ថាគោលបំណងនៃកិច្ចការគឺផ្តល់នូវការផ្តោតអារម្មណ៍យ៉ាងពិតប្រាកដមួយសម្រាប់ការប្រើប្រាស់ភាសា និងការបង្កើតនូវបរិបទធម្មតាសម្រាប់ការរៀនភាសា។ លោក Frost (2004) បានបង្ហាញថានៅក្នុងជំហានមុនការដាក់កិច្ចការនេះគ្រូធ្វើឱ្យសិស្សស៊ាំទៅនឹងប្រធានបទ និងពាក្យ និងឃ្លាដែលទាក់ទងទៅនឹងប្រធានបទនៃសកម្មភាពកិច្ចការនោះ។ នៅក្នុងជំហានមុនការដាក់កិច្ចការអាចរួមបញ្ចូលទាំងការចាក់នូវសកម្មភាពរបស់មនុស្សកំពុងបំពេញកិច្ចការ ដែលអាចផ្តល់ដល់អ្នកសិក្សានូវគម្រូមួយច្បាស់លាស់ដែលរំពឹងទុកពីពួកគេ។ អ្នកសិក្សាអាចកត់ត្រានូវចំណុចមួយចំនួននិងចំណាយពេលវេលាក្នុងការរៀបចំសម្រាប់កិច្ចការរបស់ខ្លួន។

### ២. ជំហានការដាក់កិច្ចការ

លោក Prabhu (1987) បានបង្ហាញថានៅក្នុងជំហាននេះ អ្នកសិក្សាធ្វើសកម្មភាពដោយខ្លួនឯង។ ពួកគេអាចបំពេញកិច្ចការជាគូ ឬជាក្រុមតូចខណៈពេលដែលគ្រូកំពុងតែសង្កេតពីពួកគេជាប្រចាំ។ ក្នុងជំហាននេះផ្តល់ឱកាសសម្រាប់ការនិយាយ និងសរសេរដើម្បីឱ្យពួកគេអាចរៀនពីគ្នាទៅវិញទៅមកបាន។ បន្ទាប់មកអ្នកសិក្សាអាចបង្កើតជាគម្រោងពីរបៀបប្រាប់ក្រុមដទៃផ្សេងទៀតនូវអ្វីដែលពួកគេបានធ្វើ និងទៅដោយរបៀបណា។ បន្ទាប់មកពួកគេរាយការណ៍ដោយផ្ទាល់មាត់ ឬតាមរយៈការសរសេរ និងប្រៀបធៀបការកត់ត្រានូវអ្វីដែលបានកើតឡើង។ យោងទៅតាមភាសាវិទ្យា វដ្តនៃកិច្ចការមានបីសំខាន់គឺ កិច្ចការ (សកម្មភាព) ផែនការ (កន្លែងដែលអ្នកសិក្សាគ្រោងរបាយការណ៍របស់ពួកគេយ៉ាងមានប្រសិទ្ធភាពនិងស្វែងរកឱកាសពីការរៀនរបស់ពួកគេ) និងរាយការណ៍។

### ៣. ជំហានកិច្ចការចុងក្រោយ

ដោយយោងទៅតាម Willis (1996) បានបង្ហាញថាជំហានចុងក្រោយនៃការដាក់កិច្ចការគឺជាជំហានបន្ទាប់ដែលសកម្មភាពសំខាន់ៗត្រូវបានសម្រេចរួចរាល់។ ជំហានកិច្ចការ

ចុងក្រោយផ្តល់ការពិនិត្យបញ្ចប់ និងការវិភាគនូវទិដ្ឋភាពខ្លះៗដែលបានកើតឡើងក្នុងការប្រើប្រាស់ភាសាក្នុងកំឡុងពេលវដ្តនៃកិច្ចការ (Skehan, 1996)។ លោក Willis (1996) បានបង្ហាញថាជំហាននេះ ដំបូងអ្នកសិក្សាអាចអនុវត្តជាសាធារណៈកន្លែងដែលធ្វើកិច្ចការម្តងទៀតជាមួយនឹងសិស្សក្នុងថ្នាក់ ក្រុមដទៃផ្សេងទៀត ឬគ្រូជាអ្នកមើល។ ធ្វើដូចនេះអ្នកសិក្សាមានឱកាសផ្សេងទៀតនូវក្នុងការប្រើប្រាស់ខ្លឹមសារមេរៀន។ ទីពីរ អ្នកសិក្សាអាចផ្តោតទៅលើសកម្មភាពភាសាដូចជា ការអនុវត្តនូវឃ្លា ប្រយោគ ពាក្យ និងសំណាងប្រយោគផ្សេងៗ (Willis, 1996)។ ទីបី អ្នកសិក្សាអាចចូលរួមនៅក្នុងការកែទាំងខ្លឹមសារ និងភាសា។ ជាចុងក្រោយគឺ គ្រូផ្តល់ជាព័ត៌មានត្រឡប់អំពីភាពត្រឹមត្រូវនៃការប្រើប្រាស់ភាសា។

លោក Crookes និង លោក Grass (1993) បានលើឡើងថាអ្នកស្រាវជ្រាវ និង ភាសាវិទ្យាសម្រាប់រយៈពេលវែងបានរកឃើញនៅគោលវិធីដ៏ល្អបំផុត ដែលមានប្រយោជន៍សម្រាប់ការរៀន និងបង្រៀនភាសា។ សញ្ញាណនៃគោលវិធីនេះគឺជួយអ្នកសិក្សាដើម្បីរៀនខ្លឹមសារមេរៀនដោយបង្ហាញសកម្មភាពផ្តោតលើកិច្ចការមានន័យពេញលេញ។

## ២.៩. និយមន័យពាក្យគន្លឹះ

វិធីសាស្ត្របង្រៀនៈ ជាវិធីបង្រៀនភាសាដែលផ្អែកលើគោលការណ៍ និងនិតិវិធីជាប្រព័ន្ធ (Schmidt, 2010, p. 363)។ វិធីសាស្ត្រមួយគឺជាការសម្រេចជាក់ស្តែងនៃយុទ្ធវិធីមួយ។ អ្នកបង្កើតវិធីសាស្ត្រមួយបានឈានដល់ការសម្រេចិត្តអំពីប្រភេទនៃសកម្មភាព តួនាទីរបស់គ្រូ និងអ្នកសិក្សា ប្រភេទនៃសម្ភារឧបទ្ទេសដែលនឹងមានប្រយោជន៍ និង គម្រូខ្លះៗ នៃការរៀបចំកម្មវិធីសិក្សា។ វិធីសាស្ត្ររួមមាននិតិវិធី និងបច្ចេកទេសផ្សេងៗដែលជាផ្នែកមួយនៃស្តង់ដាររបស់ពួកគេ (Harmer, 2007, p. 62)។

Method មកពីពាក្យក្រិច 'methodos', (meta: after),(hodos: way)
វចនានុក្រមផ្តល់ន័យដូចជា៖

- របៀបនៃដំណើរការ ឬនីតិវិធី

- របៀបលំដាប់លំដោយ ឬជាប្រព័ន្ធ
- វិធីនៃការធ្វើអ្វីមួយដែលស្របទៅនឹងផែនការច្បាស់លាស់
- វិធីដែលបានបង្កើតឡើងដើម្បីធ្វើអ្វីម្យ៉ាង
- មធ្យោបាយ ឬលក្ខណៈដែលអ្វីមួយត្រូវបានបង្ហាញ ឬបង្រៀន។

ក្នុងការបង្រៀន Method គឺ៖

- សេរីនៃទង្វើទាក់ទងគ្នាជាលំដាប់ដែលអនុវត្តដោយគ្រូនិងសិស្ស ដើម្បីសម្រេចគោលបំណងទូទៅនិងជាក់លាក់នៃមេរៀនមួយ
- បង្កើតស្ពានរវាងគ្រូនិងអ្នកសិក្សា
- រួមបញ្ចូលអ្វីមួយដែលគ្រូបង្រៀនធ្វើ ឬមិនបានធ្វើដែលជួយឱ្យអ្នកសិក្សាមានការផ្លាស់ប្តូរ
- វិធីដែលគ្រូបង្រៀនប្រើដើម្បីផ្ទេរ ឬទទួល ឬចែករំលែកព័ត៌មាន
- ដំណើរការនៃការចែកចាយចំណេះដឹង និងជំនាញដែលត្រូវបានប្រើដោយគ្រូបង្រៀននៅក្នុងថ្នាក់រៀន។

សរុបមក វិធីសាស្ត្របង្រៀនសំដៅទៅលើគោលការណ៍ទូទៅ គរុកោសល្យ និងយុទ្ធសាស្ត្រគ្រប់គ្រងថ្នាក់ដែលប្រើសម្រាប់ការបង្ហាត់បង្រៀន (ក្រសួងអប់រំយុវជននិងកីឡា, ២០១៩)។

ប្រសិទ្ធភាព: គឺជាការផ្តល់នូវអ្វីដែលកម្មភាពមួយបំពេញគោលបំណងជាក់លាក់ ឬមុខងាររបស់វា។ មានន័យថា អំណាចដ៏ក្លាខ្លាំង កម្លាំង (ហុកថេន, ២០០៧, ទំព័រ ៦១១)។

សរុបមក វិធីសាស្ត្របង្រៀន គឺជាគោលការណ៍ និងវិធីសាស្ត្រដែលត្រូវប្រើដោយគ្រូដើម្បីជួយដល់ការសិក្សារបស់សិស្ស។ វិធីសាស្ត្រនេះត្រូវបានកំណត់ដោយផ្អែកលើប្រធានបទដែលត្រូវបង្រៀន និងមួយផ្នែកទៀតដោយកម្រិតរបស់អ្នកសិក្សា។

Fraser (1994, p. 104) គឺជារង្វាស់នៃការប្រកួតរវាងគោលដៅដែលបានបញ្ជាក់និងសមិទ្ធផលរបស់ពួកគេ។ វាតែងតែអាចទៅរួចដើម្បីសម្រេចបាននូវគោលដៅដែលមានលក្ខណៈ "ងាយស្រួល" និងទាប។ និយាយម្យ៉ាងទៀតថា គុណភាពនៃការអប់រំជាន់ខ្ពស់មិនត្រឹមតែជាសំណួរមួយនៃសមិទ្ធផលប៉ុណ្ណោះទេ ប៉ុន្តែក៏ត្រូវតែមានការវិនិច្ឆ័យអំពីគោលដៅផងដែរ (ជាផ្នែកមួយនៃ "ធាតុចូល")។

លោកErlendsson (2002) វិសាលភាពដែលគោលដៅត្រូវបានជួបប្រជុំគ្នា "ការធ្វើរឿងត្រឹមត្រូវ"។

UNESCO បានឱ្យនិយមន័យថា លទ្ធផលនៃការពិនិត្យឡើងវិញ/ការវិភាគជាក់លាក់ដែលវាស់វែងគុណភាពនៃការសម្រេចបាននូវគោលដៅអប់រំជាក់លាក់ ឬកម្រិតដែលគ្រឹះស្ថានឧត្តមសិក្សាអាចរំពឹងថានឹងទទួលបាននូវតម្រូវការជាក់លាក់។ វាខុសពីប្រសិទ្ធផលដែលត្រូវបានវាស់ដោយកម្រិតនៃទិន្នផល ឬការបញ្ចូលដែលត្រូវបានប្រើ។ ជារង្វាស់ចម្បងនៃភាពជោគជ័យនៃកម្មវិធីនៃគ្រឹះស្ថានឧត្តមសិក្សាសូចនាករច្បាស់លាស់ព័ត៌មានសំខាន់ៗ និងភ័ស្តុតាងដែលឆ្លុះបញ្ចាំងពីប្រសិទ្ធភាពស្ថាប័ន ដោយយកចិត្តទុកដាក់លើការរៀនសូត្ររបស់សិស្ស និងសមិទ្ធផលសិក្សាត្រូវតែប្រមូលផ្តុំតាមនីតិវិធីផ្សេងៗគ្នា (អធិការកិច្ច ការអង្កេតមើលទីកន្លែង)។ ការចូលរួមក្នុងការវាស់វែងប្រសិទ្ធភាពអប់រំ បង្កើននូវតម្លៃបន្ថែមតាមរយៈការធានាគុណភាពនិងការពិនិត្យឡើងវិញនូវការទទួលស្គាល់ និងរួមចំណែកដល់ការកសាងនូវភស្តុតាងនៅក្នុងស្ថាប័ន (Lazăr Vlăsceanu, 2004, p. 36)។

Wojtczak (2002) ជារង្វាស់នៃវិសាលភាពដែលមានការអន្តរាគមន៍ជាក់លាក់ នីតិវិធីការព្យាបាល ឬសេវាជាក់លាក់នៅពេលដែលបានដាក់ពង្រាយនៅលើវាលក្នុងកាលៈទេសៈជាប្រចាំធ្វើអ្វីដែលវាត្រូវបានធ្វើឡើងដើម្បីប្រជាជនដែលបានបញ្ជាក់។ នៅក្នុងវិស័យសុខាភិបាលវាគឺជារង្វាស់នៃទិន្នផលពីសេវាសុខភាពទាំងនោះ ដែលរួមចំណែកដល់ការកាត់បន្ថយវិមាត្រនៃបញ្ហា ឬការធ្វើឱ្យប្រសើឡើងនូវស្ថានភាពមិនពេញចិត្ត។

# ជំពូកទី៣

# វិធីសាស្ត្រស្រាវជ្រាវ

# ជំពូកទី៣៖ វិធីសាស្ត្រស្រាវជ្រាវ

នៅក្នុងជំពូកនេះ នឹងធ្វើការបញ្ជាក់អំពីរបៀបនៃការស្រាវជ្រាវ និងវិធីទាំងឡាយក្នុងការប្រមូលទិន្នន័យ វិភាគទិន្នន័យ និងក្រមសីលធម៌ក្នុងការចុះយកទិន្នន័យ។

## ៣.១. ការរៀបចំការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ នឹងអនុវត្តក្នុងទម្រង់ជាករណីសិក្សានៅតាមអនុវិទ្យាល័យនៅក្នុងរាជធានីភ្នំពេញ។ ដើម្បីឆ្លើយតបទៅនឹងសំណួរស្រាវជ្រាវដែលបានបញ្ជាក់ក្នុងជំពូកទី១ ការសិក្សានេះត្រូវបានប្រើប្រាស់វិធីសាស្ត្រពីរប្រភេទក្នុងការចុះប្រមូលទិន្នន័យ គឺការសិក្សាតាមបែបបរិមាណវិស័យ (Quantitative Method) និងតាមបែបគុណវិស័យ (Qualitative Method) ឬហៅម្យ៉ាងទៀតថាវិធីសាស្ត្រចម្រុះ (Mixed Methods)។ វិធីសាស្ត្រចម្រុះមានសារៈសំខាន់ណាស់សម្រាប់ការសិក្សាស្រាវជ្រាវ ព្រោះវាអាចជួយឱ្យអ្នកសិក្សាស្រាវជ្រាវធ្វើការរុករកនៅអ្វីផ្សេងទៀតកាន់តែស៊ីជម្រៅជាងការប្រើប្រាស់វិធីសាស្ត្រតែមួយប្រភេទ។

ក្នុងការសិក្សាស្រាវជ្រាវតាមបែបគុណវិស័យ អ្នកស្រាវជ្រាវនឹងប្រើប្រាស់កម្រងសំណួរជាទម្រង់បើកនិងមានភាពទន់ភ្លន់ទៅតាមស្ថានភាពជាក់ស្តែង ព្រមទាំងធ្វើការសង្កេតនៅតាមអនុវិទ្យាល័យគោលដៅផងដែរដើម្បីជាការបំពេញ និងស្វែងយល់នូវព័ត៌មានបន្ថែមទៀត។ វិធីសាស្ត្រតាមបែបគុណវិស័យធ្វើឱ្យអ្នកសិក្សាស្រាវជ្រាវស្វែងរកព័ត៌មានកាន់តែស៊ីជម្រៅទៅលើបញ្ហាដែលមានឥទ្ធិពលផ្ទាល់ទៅនឹងស្ថានភាពជាក់ស្តែង។ វិធីសាស្ត្រនេះបានផ្តល់ឱកាសដល់អ្នកឆ្លើយបង្ហាញនូវអ្វីជាការព្រួយបារម្ភណ៍របស់ខ្លួន។ ការសិក្សាតាមបែបគុណវិស័យធ្វើឱ្យអ្នកសិក្សាក្តាប់បាននូវបញ្ហាជាក់លាក់ជាង។

ចំពោះការស្រាវជ្រាវតាមបែបបរិមាណវិស័យវិញ អ្នកស្រាវជ្រាវប្រើប្រាស់កម្រងសំណួរបែបទម្រង់បិទដើម្បីឱ្យអ្នកឆ្លើយជ្រើសរើសនូវចម្លើយ ដែលអ្នកស្រាវជ្រាវបានរៀបចំទុករួចជាស្រាច់។ វិធីសាស្ត្រនេះ វាងាយស្រួលក្នុងការបំពេញ ហើយប្រើប្រាស់ពេលវេលាតិច ដោយអ្នកឆ្លើយគ្រាន់តែចំណាយពេលអាន និងជ្រើសរើសចម្លើយដែលពួកគាត់ពេញចិត្តតែប៉ុណ្ណោះ។

## ៣.២. ឧបករណ៍ស្រាវជ្រាវ

ចំពោះឧបករណ៍សម្រាប់ការស្រាវជ្រាវវិញ អ្នកស្រាវជ្រាវបានរៀបចំបង្កើតជាកម្រងសំណួរដែលមានលក្ខណៈជាទម្រង់បិទ និងទម្រង់បើកផងដែរសម្រាប់ឱ្យក្រុមគោលដៅធ្វើការបំពេញ និងឆ្លើយតាមសំណួរទៅតាមការយល់ឃើញរបស់ពួកគេ។ ដោយសារតែគោលបំណងនៃការស្រាវជ្រាវរបស់អ្នកសិក្សាស្រាវជ្រាវ ចង់រកឱ្យឃើញនូវភាពញឹកញាប់ក្នុងការប្រើប្រាស់វិធីសាស្ត្របង្រៀន និងប្រសិទ្ធភាពរបស់វិធីសាស្ត្រដែលគ្រូបានប្រើនោះ អ្នកដែលពាក់ព័ន្ធក្នុងការស្រាវជ្រាវនេះមានតែគ្រូបង្រៀនផ្ទាល់ដែលប្រើប្រាស់វិធីសាស្ត្រក្នុងការបង្រៀន និងសិស្សដែលជាអ្នកទទួលនូវព័ត៌មានពីគ្រូតែប៉ុណ្ណោះ។ ដូច្នេះអ្នកស្រាវជ្រាវសម្រេចជ្រើសរើសយកតែអ្នកពាក់ព័ន្ធតែពីរប៉ុណ្ណោះ គឺគ្រូបង្រៀន និងសិស្សដែលលោកគ្រូ អ្នកគ្រូបានបង្រៀន។ កម្រងសំណួរត្រូវបានរៀបចំតែពីរប្រភេទប៉ុណ្ណោះគឺ កម្រងសំណួរសម្រាប់គ្រូបង្រៀន និងកម្រងសំណួរសម្រាប់សិស្ស។ កម្រងសំណួរនេះចែកចេញជាបីផ្នែកសំខាន់ៗគឺៈ

ផ្នែកទី១ៈ ជាព័ត៌មានទូទៅសម្រាប់ឱ្យអ្នកចូលរួមបំពេញមានដូចជា បទពិសោធបង្រៀន កម្រិតសញ្ញាបត្រ និងក្របខណ្ឌ។

ផ្នែកទី២ៈ ជាសូចនាករបច្ចេកទេសនៅក្នុងសកម្មភាពនៃការបង្រៀនរបស់គ្រូដែលបានប្រើប្រាស់នៅពេលបង្រៀនសិស្ស។

ផ្នែកទី៣ៈ ជាសូចនាករដែលទាក់ទងទៅនឹងប្រសិទ្ធភាពនៃការបង្រៀនដោយប្រើប្រាស់វិធីសាស្ត្របង្រៀន ដែលលោកគ្រូ អ្នកគ្រូបានជ្រើសរើសយកមកប្រើដើម្បីជួយសិស្សឱ្យឆាប់ទទួលបានព័ត៌មានទៅតាមវត្ថុបំណងនៃមេរៀនដែលគ្រូបានរៀបចំទុកជាស្រេច។

## ៣.៣. វិធីសាស្ត្រជ្រើសរើសភាគសំណាក

ការជ្រើសរើសភាគសំណាក គឺជាផ្នែកមួយយ៉ាងសំខាន់និងត្រូវធ្វើឡើងដោយប្រុងប្រយ័ត្នដើម្បីទទួលបាននូវព័ត៌មានជាក់លាក់ពិតប្រាកដនិងមានតម្លៃជាសកល។ ហេតុនេះហើយ អ្នកស្រាវជ្រាវប្រើវិធីជ្រើសរើសភាគសំណាកពីសាលាជាច្រើនដើម្បីបានព័ត៌មានពិតមកវិភាគឱ្យបានត្រឹមត្រូវ ច្បាស់លាស់ និងស៊ីជម្រៅ។ ចំពោះភាគសំណាគឺជ្រើសរើសយកគ្រូ

បង្រៀនភាសាអង់គ្លេសចំនួន ៣២នាក់ ដែលកំពុងបង្រៀនមុខវិជ្ជាភាសាអង់គ្លេសនៅមធ្យមសិក្សាបឋមភូមិដែលជាសាលាគោលដៅសម្រាប់ធ្វើការស្រាវជ្រាវ។ ដោយចំនួនអនុវិទ្យាល័យនៅក្នុងរាជធានីភ្នំពេញមានចំនួនច្រើន ដូចនេះអ្នកស្រាវជ្រាវមិនអាចជ្រើសរើសយកសាលាទាំងអស់មកធ្វើការស្រាវជ្រាវបានទេ ព្រោះពេលវេលាមានកំណត់។ ដូច្នេះអ្នកស្រាវជ្រាវបានជ្រើសរើសយកតែសាលាចំនួន១២ប៉ុណ្ណោះមកធ្វើជាសាលាគោលដៅសម្រាប់ការស្រាវជ្រាវ។ សាលាទាំងនោះស្ថិតក្នុងបីតំបន់ផ្សេងៗគ្នា គឺតំបន់ទីប្រជុំជន តំបន់ជាយក្រុង និងតំបន់ដាច់ស្រយាល ដែលក្នុងមួយតំបន់ជ្រើសរើសយក ៤សាលា គឺតំបន់ទីប្រជុំជនមាន៤សាលា ដូចជាអនុវិទ្យាល័យចតុមុខ អនុវិទ្យាល័យសុធារស អនុវិទ្យាល័យអូរបែកក្អម និងអនុវិទ្យាល័យ វត្តនាគវ័ន។ ចំពោះតំបន់ជាយក្រុងវិញមាន៤សាលាដែរគឺ អនុវិទ្យាល័យហ៊ុនសែនចម្រើនជាតិ អនុវិទ្យាល័យទួលសុវណ្ណារាម អនុវិទ្យាល័យព្រែកព្នៅ និងអនុវិទ្យាល័យព្រែករាំង។ រីឯតំបន់ដាច់ស្រយាលមានចំនួន៤សាលាគឺ អនុវិទ្យាល័យទួលស្នោរ អនុវិទ្យាល័យឪឡោក អនុវិទ្យាល័យចំបក់មាស និងអនុវិទ្យាល័យហ៊ុនសែនពញាពន់។ ចំនួនគ្រូដែលត្រូវជ្រើរើសមានចំនួន ៣២នាក់ និងសិស្សត្រូវបានជ្រើសរើសចេញពីគ្រូក្នុងមួយនាក់យកសិស្សចំនួន ១០នាក់ សម្រាប់បំពេញកម្រងសំណួរ។

## ៣.៤. ការប្រមូលទិន្នន័យ

### ៣.៤.១. ទំហំនៃភាគសំណាក និងមុខសញ្ញាដែលត្រូវយកទិន្នន័យ

ទិន្នន័យដែលទទួលបានក្នុងទម្រង់ពីរផ្សេងគ្នាគឺ តាមរយៈការបំពេញកម្រងសំណួរដែលមានកម្រងសំណួរសម្រាប់គ្រូបំពេញ និងកម្រងសំណួរសម្រាប់សិស្សបំពេញ និងតាមរយៈការសម្ភាសផ្ទាល់ជាមួយនឹងលោកគ្រូ អ្នកគ្រូ ដែលកំពុងបង្រៀនភាសាអង់គ្លេសនៅតាមសាលាគោលដៅទាំង១២។ ការយកទិន្នន័យ ឬសំណាកគំរូគឺអ្នកសិក្សាស្រាវជ្រាវជ្រើសរើសយកសំណាកចំនួន ៤៣២ នាក់ដែលក្នុងនោះ លោកគ្រូអ្នកគ្រូដែលកំពុងបង្រៀនមុខវិជ្ជាភាសា

អង់គ្លេសចំនួន ៣២ នាក់មកពីសាលាចំនួន ១២ ផ្សេងៗគ្នា និងសិស្សចំនួន ៤០០ នាក់មកពីសិស្សដែលលោកគ្រូ អ្នកគ្រូកំពុងបង្រៀនផ្សេងៗគ្នាដែរ។

### ៣.៤.២. ការសិក្សាសាកល្បង

មុនពេលចុះប្រមូលទិន្នន័យពិតប្រាកដ អ្នកស្រាវជ្រាវបានធ្វើការសិក្សាសាកល្បងក្នុងទម្រង់តូចមួយ ដោយធ្វើការជ្រើសរើសលោកគ្រូអ្នកគ្រូដែលកំពុងបង្រៀនភាសាអង់គ្លេសពីថ្នាក់ទី៧ដល់ថ្នាក់ទី៩ ចំនួន ៣នាក់ និងសិស្សចំនួន ៣០នាក់មកពី៣ថ្នាក់ផ្សេងៗគ្នាឱ្យជួយបំពេញនូវកម្រងសំណួរ និងសម្ភាសជាទម្រង់សាកល្បង។ គោលបំណងនៃការសាកល្បងកម្រងសំណួរនេះ គឺដើម្បីធានាអំពីប្រសិទ្ធភាព និងភាពពិតប្រាកដនៃកម្រងសំណួរនិងធានាថាអាចយកមកប្រមូលទិន្នន័យជាក់ស្តែងបានប្រកបដោយភាពជឿជាក់ខ្ពស់។ ចំពោះការសាកល្បងនេះ អ្នកស្រាវជ្រាវបានរកឃើញថា ការបំពេញកម្រងសំណួរដែលបានរៀបចំឱ្យគ្រូនិងសិស្សបំពេញក្នុងរយៈពេលលើសពី ១៥នាទី នេះគឺមិនអាចទៅរួចទេ ព្រោះគ្រូនិងសិស្សជាប់ភារកិច្ចបង្រៀន និងរៀន ដោយការចេញលេងគឺមានតែរយៈពេល១៥នាទីតែប៉ុណ្ណោះ។ បន្ទាប់ពីបានបំពេញកម្រងសំណួររួចហើយដោយប្រើរយៈពេលវែង លោកគ្រូអ្នកគ្រូក៏សំណូមពរឱ្យកាត់បន្ថយពេលវេលាមួយចំនួន ព្រមទាំងដកចេញនូវសំណួរដែលមិនចាំបាច់ដល់ការសិក្សាស្រាវជ្រាវនេះ។ អ្នកស្រាវជ្រាវក៏បានយល់ព្រមតាមសំណើនេះ ដោយយកសំណើទាំងនោះមកពិភាក្សាជាមួយសាស្ត្រាចារ្យដឹកនាំបង្គោល និងសាស្ត្រាចារ្យដឹកនាំរង ដើម្បីធ្វើការកែតម្រូវទៅលើកម្រងសំណួរទាំងនោះ។ ក្រោយពីទទួលបានការណែនាំ និងឯកភាពពីសាស្ត្រាចារ្យដឹកនាំបង្គោល និងសាស្ត្រាចារ្យដឹកនាំរងរួចមក អ្នកសិក្សាស្រាវជ្រាវក៏ចាប់ផ្តើមចុះប្រមូលទិន្នន័យតែម្តង។

### ៣.៥. ដំណាក់កាលនៃការប្រមូលទិន្នន័យ

ក្រោយពីទទួលបាននូវការណែនាំ និងឯកភាពពីសាស្ត្រាចារ្យដឹកនាំបង្គោល និងសាស្ត្រាចារ្យដឹកនាំរង ព្រមទាំងលិខិតរបស់វិទ្យាស្ថានជាតិអប់រំ លេខ ១៨៨៥ អយក.វជអ ចុះថ្ងៃ

ទី ១៨ ខែមេសា ឆ្នាំ ២០១៩ ស្នើទៅប្រធានមន្ទីរអប់រំយុវជន និងកីឡារាជធានីភ្នំពេញដើម្បីសុំកិច្ចសហការ ដើម្បីជួយសម្រួលដល់ការចុះប្រមូលទិន្នន័យនៅសាលាគោលដៅនៅក្នុងរាជធានីភ្នំពេញរួចមក អ្នកស្រាវជ្រាវក៏បានរៀបចំផែនការចុះទៅទំនាក់ទំនងលោកប្រធានមន្ទីរអប់រំយុវជន និងកីឡារាជធានីភ្នំពេញ ដើម្បីសុំសេចក្តីអនុញ្ញាតឱ្យអ្នកសិក្សាស្រាវជ្រាវចុះទៅកាន់សាលាគោលដៅដែលនៅក្រោមការគ្រប់គ្រងរបស់ខ្លួន ដើម្បីសុំកិច្ចសហការក្នុងការប្រមូលទិន្នន័យដែលទាក់ទងទៅនឹងប្រធានបទសម្រាប់ធ្វើការវិភាគ។ ក្រោយពីបានទទួលការអនុញ្ញាតពីលោកប្រធានមន្ទីរអប់រំយុវជន និងកីឡារាជធានីភ្នំពេញរួចមក អ្នកស្រាវជ្រាវក៏បានទៅទំនាក់ទំនងដោយផ្ទាល់ជាមួយសាលាគោលដៅ ដើម្បីសុំការអនុញ្ញាតពីគណៈគ្រប់គ្រងសាលាក្នុងការកំណត់ការបរិច្ឆេទជួបសម្ភាសជាមួយលោកគ្រូអ្នកគ្រូដែលកំពុងបង្រៀនមុខវិជ្ជាភាសាអង់គ្លេស និងសិស្ស ១០នាក់ក្នុងមួយថ្នាក់ក្នុងគោលបំណងធ្វើយ៉ាងណាមិនឱ្យប៉ះពាល់ដល់ការបង្រៀនរបស់លោកគ្រូអ្នកគ្រូ និងការសិក្សារបស់សិស្សានុសិស្សនោះទេ។

## ៣.៦. ការវិភាគទិន្នន័យ

ការសិក្សាស្រាវជ្រាវនេះ បានប្រើប្រាស់នូវវិធីសាស្ត្រទាំងពីរបែបគឺ បរិមាណវិស័យ និងគុណវិស័យ ដើម្បីពិពណ៌នាអំពីស្ថានភាពទូទៅនៃការបង្រៀនភាសាអង់គ្លេសនៅក្នុងរាជធានីភ្នំពេញ ព្រមទាំងឆ្លុះបញ្ចាំងទៅលទ្ធផលសិក្សារបស់សិស្សទៀតផង។ ចំពោះទិន្នន័យដែលត្រូវប្រមូលបានពីកម្រងសំណួរ យើងនឹងវិភាគតាមបែបបរិមាណវិស័យដោយប្រើកប្រាស់ម្មវិធី SPSS ដើម្បីគណនារក Frequency និងភាពច្បាស់លាស់នៃសំណួរដែលត្រូវបំពេញ និង MS. Excel ដើម្បីសង់ក្រាប និងវិភាគ ។

ចំពោះទិន្នន័យបែបគុណវិស័យ ដែលទទួលបានតាមរយៈកម្រងសំណួរបើក ត្រូវបានអាន និងវិភាគដោយធ្វើចំណាត់ថ្នាក់ទៅតាមប្រធានបទនីមួយៗ ដើម្បីឆ្លើយតបទៅនឹងសំណួរស្រាវជ្រាវស្តីពីការរៀន និងបង្រៀនភាសាអង់គ្លេស និងប្រសិទ្ធភាពនៃវិធីសាស្ត្រដែលគ្រូប្រើ

ញឹកញាប់ជាងគេនៅមធ្យមសិក្សាបឋមភូមិ។ លើសពីនេះទៀត ព័ត៌មានទាំងនេះត្រូវបានប្រើប្រាស់ដើម្បីពិភាក្សាលើលទ្ធផលដែលបានពីទិន្នន័យបែបបរិមាណវិស័យផងដែរ។

## ៣.៧. ក្រមសីលធម៌នៃការស្រាវជ្រាវ

អ្នកសិក្សាស្រាវជ្រាវ មានការយកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះក្រមសីលធម៌ក្នុងការចុះស្រាវជ្រាវ ពីព្រោះវាមានសារៈសំខាន់ណាស់ក្នុងការធានាបាននូវប្រសិទ្ធភាពនៃការស្រាវជ្រាវក៏ដូចជាការបង្កើននូវសេចក្ដីទុកចិត្ត និងភាពជឿជាក់ដល់អ្នកចូលរួមផ្ដល់ចម្លើយសម្រាប់យកមកប្រើប្រាស់នៅក្នុងកិច្ចការស្រាវជ្រាវនេះ។ មុនពេលចុះទៅប្រមូលទិន្នន័យនៅតាមសាលាគោលដៅ វិទ្យាស្ថានជាតិអប់រំបានរៀបចំសំណើដើម្បីសុំសេចក្ដីអនុញ្ញាតិពីក្រសួងអប់រំយុវជន និងកីឡា ក្នុងការធ្វើការប្រមូលទិន្នន័យនៅតាមសាលាគោលដៅយកមកវិភាគនៅក្នុងការស្រាវជ្រាវ។ បន្ទាប់ពីបានលិខិតឧទ្ទេសនាមពីវិទ្យាស្ថានជាតិអប់រំដើម្បីសុំកិច្ចសហការណ៍ពីលោកលោកស្រីប្រធានអង្គភាពដែលចេញឱ្យនិស្សិតយកមកធ្វើជាលិខិតអមនោះ អ្នកស្រាវជ្រាវបានយកលិខិតនេះទៅកាន់មន្ទីរអប់រំ យុវជន និងកីឡា រាជធានីភ្នំពេញ ដើម្បីសុំចំណារបន្ថែមពីប្រធានមន្ទីរអប់រំយុវជន និងកីឡារាជធានីភ្នំពេញដើម្បីឱ្យប្រធានអង្គភាពក្រោមឱវាទរបស់ខ្លួនសហការណ៍ជាមួយអ្នកស្រាវជ្រាវក្នុងការប្រមូលទិន្នន័យ។ បន្ទាប់ពីបានទទួលលិខិតរបស់មន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញបានហើយ អ្នកស្រាវជ្រាវបានយកលិខិតដែលមានចំណាររបស់ប្រធានមន្ទីរ យកទៅប្រគល់ជូនប្រធានអង្គភាពនៅគ្រប់សាលាគោលដៅដែលអ្នកស្រាវជ្រាវបានកំណត់រួចហើយមុនពេលបំពេញកម្រងសំណួរ និងសម្ភាស។ ការធ្វើបែបនេះ បានធ្វើឱ្យអ្នកសិក្សាស្រាវជ្រាវមានទំនុកចិត្ត និងមាន ភស្ដុតាងគ្រប់គ្រាន់ដើម្បីបញ្ជាក់ពីភាពស្របច្បាប់របស់ខ្លួននៅក្នុងការប្រមូលទិន្នន័យ។ម្យ៉ាងវិញទៀត អ្នកផ្ដល់ចម្លើយក៏បានយល់ពីគោលបំណងនៃការសិក្សាស្រាវជ្រាវ និងមានទំនុកចិត្តថារាល់ព័ត៌មានដែលភាគសំណាកបានផ្ដល់ឱ្យនោះ ពិតជាយកទៅប្រើប្រាស់ក្នុងការសិក្សាស្រាវជ្រាវនិងបំពេញនូវចន្លោះប្រហោងដែលពួកគាត់កំពុងជួបប្រទះនាពេលបច្ចុប្បន្ននេះ។

# ជំពូកទី៤

# លទ្ធផលស្រាវជ្រាវ

# និង

# ការពិភាក្សា

# ជំពូកទី៤៖ លទ្ធផល និងការពិភាក្សា

នៅក្នុងជំពូកទី៤នេះ អ្នកសិក្សាស្រាវជ្រាវបានបង្ហាញអំពីវិធីសាស្ត្រប្រមូលទិន្នន័យ និងវិភាគទិន្នន័យ។ ទិន្នន័យត្រូវបានប្រមូលដោយប្រើកម្រងសំណួរបំពេញ និងកម្រងសំណួរសម្ភាសន៍ដូចដែលបានបង្ហាញនៅក្នុងជំពូកទី៣។ ការប្រើកម្រងសំណួរសម្ភាសន៍គឺដើម្បីប្រមូលទិន្នន័យក្នុងការសិក្សាស្រាវជ្រាវនេះ ដែលមានសារៈសំខាន់ក្នុងការស្វែងយល់ឱ្យកាន់តែស៊ីជម្រៅថែមទៀតទៅលើវិធីសាស្ត្របង្រៀន ការដឹកនាំការបង្រៀនប្រចាំថ្ងៃ និងលទ្ធផលសិក្សារបស់សិស្ស។ តាមរយៈកម្រងសំណួរបំពេញ អ្នកសិក្សាស្រាវជ្រាវខិតខំពិនិត្យ និងស្វែងយល់អំពីវិធីសាស្ត្របង្រៀនភាសាអង់គ្លេសមួយចំនួន ដែលលោកគ្រូអ្នកគ្រូនៅតាមសាលាគោលដៅដែលអ្នកសិក្សាបានកំណត់ និងជ្រើសរើសយកធ្វើជាសំណាកសម្រាប់ការសិក្សាស្រាវជ្រាវ។ អ្នកសិក្សាស្រាវជ្រាវ នឹងរកឱ្យឃើញនូវវិធីសាស្ត្របង្រៀនភាសាអង់គ្លេសណាមួយដែលលោកគ្រូ អ្នកគ្រូ ជ្រើសរើសយកមកប្រើប្រាស់ក្នុងការបង្រៀនសិស្សញឹកញាប់ជាងគេ និងប្រសិទ្ធភាពនៃវិធីសាស្ត្រនោះ។

## ៤.១. លទ្ធផលស្រាវជ្រាវ

### ៤.១.១. ព័ត៌មានទូទៅ

ក្រាបទី១៖ ចំនួនសាលា និងគ្រូចូលរួម



តាមរយៈទិន្នន័យដែលបានមកពីការបំពេញកម្រងសំណួររបស់គ្រូ ដែលបង្រៀននៅមធ្យមសិក្សាបឋមភូមិ សាលាដែលបានចូលរួមមានចំនួន ១២អនុវិទ្យាល័យដែលរួមមានចំនួនគ្រូសរុប៣២នាក់ក្នុងនោះមាន អនុវិទ្យាល័យចតុមុខគ្រូដែលបានចូលរួមមានចំនួន៦នាក់ស្មើនឹង១៨.៨% អនុវិទ្យាល័យសុធារសមានចំនួន១នាក់ស្មើនឹង៣.១% អនុវិទ្យាល័យរបែកក្អមចំនួន៦នាក់ស្មើនឹង១៨.៨% អនុវិទ្យាល័យវត្តនាគវ័នមានចំនួន៣នាក់ស្មើនឹង៩.៤% អនុវិទ្យាល័យចម្រើនជាតិមានចំនួន៣នាក់ស្មើនឹង ៩.៤% អនុវិទ្យាល័យទួលសុវណ្ណារាមមានចំនួន២នាក់ស្មើនឹង៦.៣% អនុវិទ្យាល័យព្រែកញ្ញៅមានចំនួន២នាក់ស្មើនឹង៦.៣% អនុវិទ្យាល័យព្រែករាំងមានចំនួន១នាក់ស្មើនឹង៣.១% អនុវិទ្យាល័យទួលស្នោរមានចំនួន២នាក់ស្មើនឹង៦.៣% អនុវិទ្យាល័យឪឡោកមានចំនួន២នាក់ស្មើនឹង៦.៣% អនុវិទ្យាល័យចំបក់មាសមានចំនួន១នាក់ស្មើនឹង៣.១% និងអនុវិទ្យាល័យពញាពន់មានចំនួន៣នាក់ស្មើនឹង៩.៤%។

### ៤.១.១.១. អ្នកចូលរួមជាគ្រូបង្រៀន

#### ១. អំពីភេទ និងភាគរយគ្រូចូលរួម

ក្រាបទី២៖ ភេទ និងភាគរយគ្រូ




តាមក្រាបខាងលើបានបង្ហាញថា ចំនួនគ្រូដែលបានចូលរួមសរុបចំនួន ៣២នាក់ ក្នុងនោះគ្រូប្រុសមានចំនួន១៩នាក់គិតជាភាគរយស្មើនឹង៥៩.៤% និងគ្រូស្រីចូលរួមមានចំនួន១៣នាក់គិតជាភាគរយស្មើនឹង៤០.៦%។ ដូចនេះចំនួនគ្រូប្រុសបានចូលរួមចំនួនច្រើនជាងគ្រូដែលជាស្ត្រី។

### ២. កម្រិតវប្បធម៌ទូទៅ

ក្រាបទី៣៖ កម្រិតវប្បធមិទូទៅរបស់គ្រូ




ក្រាបទី៣បានបង្ហាញថា គ្រូចំនួន៣២នាក់ដែលបានចូលរួមបំពេញកម្រងសំណួរសុទ្ធតែបានបញ្ចប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិគិតជាភាគរយស្មើនឹង១០០% ។ ដូចនេះគ្មានគ្រូណាម្នាក់ត្រូវបានក្រសួងអប់រំយុវជន និងកីឡាយកមកបំពេញរូបមន្តដើម្បីឡើងកម្រិតថ្នាក់នោះទេ។

### ៣.កម្រិតបណ្តុះបណ្តាលវិជ្ជាជីវៈ

ក្រាបទី៤៖ កម្រិតបណ្តុះបណ្តាលវិជ្ជាជីវៈ




តាមក្រាបទី៤បានបង្ហាញថា គ្រូដែលកំពុងបង្រៀនមុខវិជ្ជាភាសាអង់គ្លេសនៅតាមអនុវិទ្យាល័យគោលដៅទាំង១២ ដែលមានចំនួន៣២នាក់គឺជាគ្រូបង្រៀនកម្រិតមូលដ្ឋានដែលគិតជាភាគរយស្មើនឹង១០០%។ ដូចនេះតាមលទ្ធផលខាងលើបានបង្ហាញថាគ្រូដែលកំពុងបម្រើ

ការងារបង្រៀននៅមធ្យមសិក្សាបឋមភូមិ សុទ្ធតែជាបង្រៀនកម្រិតមូលដ្ឋានដែលបានបណ្តុះបណ្តាលនៅមធ្យមសិក្សាគរុកោសល្យទាំងអស់។ គ្មានគ្រូបង្រៀនកម្រិតបឋម ឬគ្រូបង្រៀនកម្រិតឧត្តមណាម្នាក់កំពុងបម្រើការងារនៅមធ្យមសិស្សាបឋមភូមិ ដែលនៅដាច់ដោយឡែកពីបឋមសិក្សា ឬមធ្យមសិក្សាទុតិយភូមិឡើយ។

### ៤. ឯកទេស

ក្រាបទី៥៖ ឯកទេសរបស់គ្រូបង្រៀន




តាមក្រាបខាងលើបានបង្ហាញថា ក្នុងចំណោមគ្រូ៣២នាក់ដែលកំពុងបង្រៀនភាសាអង់គ្លេសនៅតាមសាលាគោលដៅមាន២៨នាក់ គឺជាគ្រូដែលមានឯកទេសបង្រៀនជាភាសាអង់គ្លេសដែលគិតជាភាគរយស្មើនឹង៨៧.៥% ចំណែកឯគ្រូចំនួន៤នាក់ទៀតដែលកំពុងបង្រៀនភាសាអង់គ្លេសដែរនោះគឺជាគ្រូដែលមានឯកទេសផ្សេងដូចជា ឯកទេសគេហវិជ្ជាជាដើមដែលគិតជាភាគរយស្មើនឹង១២.៥%។ ដូចនេះ តាមលទ្ធផលខាងលើបានបង្ហាញថាគ្រូ

ដែលកំពុងបង្រៀនភាសាអង់គ្លេសរាល់ថ្ងៃភាគច្រើនជាគ្រូដែលមានឯកទេសដើម ហើយមានតែគ្រូតិចតួចប៉ុណ្ណោះដែលបង្រៀនខុសឯកទេស។

### ៥. ថ្នាក់បណ្តុះបណ្តាលបន្ត

ក្រាបទី៦៖ កម្រិតសញ្ញាបត្រ




តាមក្រាបខាងលើបានបង្ហាញថាក្នុងចំណោមគ្រូចំនួន៣២នាក់ដែលបានចូលរួម មានគ្រូ១២នាក់ មិនមានការបណ្តុះបណ្តាលបន្តទេ ដែលគិតជាភាគរយស្មើនឹង ៣៧.៥% ហើយគ្រូដែលបានបញ្ចប់បរិញ្ញាបត្រមានចំនួន១៩នាក់លគិតជាភាគរយស្មើនឹង៥៩.៤% និងគ្រូដែលបានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់មានចំនួន១នាក់ស្មើនឹង៣.១%។

### ៦. បទពិសោធក្នុងការបង្រៀនភាសាអង់គ្លេស

ក្រាបទី៧៖ បទពិសោធនៃការបង្រៀនភាសាអង់គ្លេស



តាមក្រាបខាងលើបានបង្ហាញថា ក្នុងចំណោមគ្រូ៣២នាក់ មានគ្រូចំនួន៥នាក់ដែលមានបទពិសោធបង្រៀនក្រោម៥ឆ្នាំស្មើនឹង១៥.៦% គ្រូចំនួន១១នាក់មានបទពិសោធបង្រៀនចាប់ពី៥ឆ្នាំដល់១០ឆ្នាំគិតជាភាគរយស្មើនឹង៣៤.៤% គ្រូចំនួន១៤នាក់មានបទពិសោធបង្រៀនចាប់ពី១១ឆ្នាំដល់១៥ឆ្នាំគិតជាភាគរយស្មើនឹង៤៣.៨% និងគ្រូចំនួន២នាក់មានបទពិសោធបង្រៀនលើ១៦ឆ្នាំស្មើនឹង៦.៣%។

### ៤.១.១.២. អ្នកចូលរួមជាសិស្ស

#### ១. អំពីសាលា និងចំនួនសិស្ស

ក្រាបទី៨៖ ចំនួនសាលារៀន និងសិស្ស




តាមក្រាបខាងលើបានបង្ហាញថា អនុវិទ្យាល័យទាំង១២នៅក្នុងរាជធានីភ្នំពេញដែលជាសាលាគោលដៅមានសិស្សចូលរួមសរុបចំនួន៤០០នាក់ ក្នុងនោះមានអនុវិ.ចតុមុខចំនួន៦០នាក់ស្មើ១៥% អនុវិ.សុធារសចំនួន២០នាក់ស្មើ៥% អនុវិ.អូរបែកក្អមចំនួន៦០នាក់ស្មើ១៥% អនុវិ.វត្តនាគវ័នចំនួន៣០នាក់ស្មើនឹង៧.៥% អនុវិ.ហាស ចម្រើនជាតិមានចំនួន៥០នាក់ស្មើនឹង១២.៥% អនុវិ.វត្តទួលសុវណ្ណារាមចំនួន២០នាក់ស្មើ៥% អនុវិ.ព្រែកព្នៅចំនួន២០នាក់ស្មើនឹង

៥%  អនុវិ.ព្រៃកវាំងមានចំនួន៣០នាក់ស្មើនឹង៧.៥%  អនុវិ.ទួលស្នោរចំនួន៣០នាក់ស្មើនឹង ៧.៥%  អនុវិ.ឪឡោកចំនួន៣០នាក់ស្មើនឹង៧.៥%  អនុវិ.ចំបក់មាសចំនួន២០នាក់ស្មើនឹង៥% និងអនុវិ.ពញាពន់ចំនួន៣០នាក់ស្មើនឹង៧.៥%។

### ២. អំពីភេទ

ក្រាបទី៩៖ ភេទ និងភាគរយសិស្សចូលរួម




តាមក្រាបខាងលើបានបង្ហាញថា  ក្នុងចំណោមសិស្ស៤០០នាក់ដែលបានចូលរួមក្នុងការបំពេញកម្រងសំណួរមានសិស្សប្រុសសរុប១៥៧នាក់ស្មើនឹង៣៩.៣% និងសិស្សស្រីចំនួន ២៤៣នាក់ស្មើនឹង៦០.៨%។ ដូចនេះសិស្សស្រីបានចូលរួមច្រើនជាងសិស្សប្រុស។

## ៤.១.២. បច្ចេកទេសក្នុងការបង្រៀន

## ៤.១.២.១. សម្រាប់គ្រូបង្រៀន

### ១. វិធីសាស្ត្រផ្ទាល់

ក្រាបទី១០៖ វិធីសាស្ត្រផ្ទាល់



តាមក្រាបខាងលើបានបង្ហាញថា ក្នុងការបង្រៀនសិស្សជារៀងរាល់ពេលក្នុងចំណោមគ្រូ៣២នាក់ មានគ្រូ១៩.២០% មិនដែលប្រើប្រាស់វិធីសាស្ត្រផ្ទាល់សោះ ចំណែកគ្រូ១៥.១៨% កម្រប្រើប្រាស់វិធីសាស្ត្រនេះណាស់ គ្រូ៥៤.៤៦%ប្រើប្រាស់វិធីសាស្ត្រនេះញឹកញាប់បំផុត និងគ្រូ១១.១៦%ប្រើប្រាស់វិធីសាស្ត្រនេះគ្រប់ពេលវេលា។ ដូចនេះតាមលទ្ធផលខាងលើបានបង្ហាញថាគ្រូដែលប្រើប្រាស់វិធីសាស្ត្រនេះមានចំនួន ៦៥.៦២%។

## ២. វិធីសាស្ត្របកប្រែ

ក្រាបទី១១៖ វិធីសាស្ត្របកប្រែ




តាមក្រាបខាងលើបានបង្ហាញថា គ្រូ៣០.៣៦% បានប្រើប្រាស់វិធីសាស្ត្របកប្រែគ្រប់ពេលក្នុងការបង្រៀនសិស្ស រីឯគ្រូ៤០.៦៣% បានប្រើប្រាស់វិធីសាស្ត្រនេះញឹកញាប់ ហើយគ្រូ១៦.៥២% កម្រប្រើប្រាស់វិធីសាស្ត្រនេះណាស់ និងគ្រូ១២.៥០% មិនដែលប្រើប្រាស់វិធីសាស្ត្រនេះទាល់តែសោះ។ ដូចនេះគ្រូ៧០.៩៩%បានប្រើប្រាស់វិធីសាស្ត្របកប្រែក្នុងការបង្រៀនសិស្ស។

### ៣. វិធីសាស្ត្របង្រៀនភាសាបែបចាក់សម្លេង

ក្រាបទី១២៖ វិធីសាស្ត្របង្រៀនភាសាបែបចាក់សម្លេង




តាមក្រាបខាងលើបានបង្ហាញថាគ្រូ៧.១៤% បានប្រើប្រាស់វិធីសាស្ត្រ The Audio Lingual Methods គ្រប់ពេលនៅពេលគាត់បង្រៀនសិស្ស គ្រូ៨.៩៣% ប្រើប្រាស់វិធីសាស្ត្រនេះញឹកញាប់ គ្រូ២៧.៦៨% កម្រប្រើប្រាស់ណាស់ និងគ្រូ៥៦.២៥% មិនដែលប្រើប្រាស់វិធីសាស្ត្រនេះទេក្នុងការបង្រៀនសិស្ស។ ដូចនេះ គ្រូភាគច្រើនមិនសូវប្រើប្រាស់វិធីសាស្ត្រ The Audio Lingual Methods ក្នុងពេលបង្រៀនសិស្សនោះទេ។

### ៤. វិធីសាស្ត្របង្រៀនភាសាបែបចាក់ភ្លេង

ក្រាបទី១៣៖ វិធីសាស្ត្របង្រៀនភាសាបែបចាក់ភ្លេង



តាមក្រាបខាងលើបានបង្ហាញថា គ្រូ៨.៤៨% បានប្រើប្រាស់វិធីសាស្ត្រ Suggestopedia គ្រប់ពេលនៅពេលបង្រៀនសិស្ស គ្រូ៨.០៩% បានប្រើប្រាស់វិធីសាស្ត្រនេះញឹកញាប់ គ្រូ២៥.០០% កម្រប្រើប្រាស់វិធីសាស្ត្រនេះវិធីសាស្ត្រនេះណាស់ និងគ្រូ៥៨.៤៨% មិនដែលប្រើប្រាស់វិធីសាស្ត្រនេះទាល់តែសោះ។ ដូចនេះ គ្រូភាគច្រើនមិនសូវប្រើប្រាស់វិធីសាស្ត្រ Suggestopedia នៅក្នុងការបង្រៀនសិស្សនោះទេ។

### ៥. វិធីសាស្ត្របង្រៀនភាសាឱ្យរាងកាយទទួល

ក្រាបទី១៤៖ វិធីសាស្ត្របង្រៀនភាសាឱ្យរាងកាយទទួល




តាមក្រាបខាងលើបានបង្ហាញថា គ្រូ៦.៧០%ប្រើប្រាស់វិធីសាស្ត្រ Total Physical Response គ្រប់ពេលនៅពេលបង្រៀនសិស្ស គ្រូ៦.៧០% ប្រើប្រាស់ញឹកញាប់ គ្រូ២៩.០២% កម្រប្រើណាស់ និងគ្រូ៥៧.៥៩%មិនដែលប្រើប្រាស់វិធីសាស្ត្រនេះសោះ។ ដូចនេះ គ្រូ៨៦.៦១% មិនបានប្រើប្រាស់វិធីសាស្ត្រនេះនៅពេលបង្រៀនសិស្សនោះទេ។

### ៦. ការបង្រៀនភាសាតាមបែបទំនាក់ទំនង

ក្រាបទី១៥៖ ការបង្រៀនភាសាតាមបែបទំនាក់ទំនង




តាមក្រាបបានបង្ហាញថា គ្រូ៥.៣៦% ប្រើប្រាស់វិធីសាស្ត្រការបង្រៀនភាសាតាមបែបទំនាក់ទំនង គ្រូ ៥.៣៦% ប្រើប្រាស់វិធីសាស្ត្រនេះញឹកញាប់ គ្រូ២៩.០២% កម្រប្រើណាស់ និង ៦០.២៧% មិនដែលប្រើសោះ។ ដូចនេះ គ្រូចំនួន៨៩.២៩% មិនប្រើប្រាស់វិធីសាស្ត្រការបង្រៀនភាសាតាមបែបទំនាក់ទំនងក្នុងការបង្រៀនសិស្សនោះទេ។

## ៧. ការរៀនភាសាតាមបែបសហគមន៍

ក្រាបទី១៦៖ ការបង្រៀនភាសាតាមបែបសហគមន៍



តាមក្រាបខាងលើបានង្ហាញថាគ្រូចំនួន៤.៩១% បានប្រើប្រាស់វិធីសាស្ត្រការបង្រៀនភាសាតាមបែបសហគមន៍គ្រប់ពេល ចំណែកឯគ្រូ៧.១៤% បានប្រើប្រាស់ញឹកញាប់ គ្រូ៣២.១៤% កម្រប្រើណាស់ និង៥៥.៨០% មិនដែលប្រើសោះ។ ដូចនេះ គ្រូចំនួន៨៧.៩៤% មិនបានប្រើប្រាស់វិធីសាស្ត្រការបង្រៀនភាសាតាមបែបសហគមន៍ទេ។

### ៨. ការបង្រៀនភាសាដោយផ្អែកលើកិច្ចការ

ក្រាបទី១៧៖ វិធីសាស្ត្របង្រៀនភាសាដោយផ្អែកលើកិច្ចការ




តាមទិន្នន័យក្រាបដែលបានពីការបំពេញកម្រងសំណួរបានបង្ហាញថា មានតែលោកគ្រូ អ្នកគ្រូចំនួន៤.៤៦% តែប៉ុណ្ណោះដែលប្រើប្រាស់វិធីសាស្ត្របង្រៀនភាសាដោយផ្អែកលើកិច្ចការគ្រប់ពេលចំណែកឯគ្រូ៦.៧០%ទៀតបានប្រើប្រាស់ញឹកញាប់ គ្រូចំនួន២១.៨៨%កម្រប្រើណាស់និងគ្រូ៦៦.៩៦%មិនដែលប្រើសោះ។ ដូចនេះគ្រូ៨៨.៨៤%មិនបានប្រើប្រាស់វិធីសាស្ត្របែកការបង្រៀនភាសាដោយផ្អែកលើកិច្ចការនោះទេ។

### ៤.១.២.២. សម្រាប់សិស្ស

ដើម្បីឱ្យប្រាកដថាព័ត៌មានដែលទទួលបានមកពីលោកគ្រូ អ្នកគ្រូដែលជាអ្នកបង្រៀនផ្ទាល់នោះពិត អ្នកស្រាវជ្រាវបានធ្វើការប្រៀបធៀបគ្រប់ចម្លើយរបស់សិស្សានុសិស្សដែលកំពុងរៀនជាមួយលោកគ្រូ អ្នកគ្រូបន្ថែមទៀត។ ទិន្នន័យដែលទទួលបានខាងលើនេះ ជាលទ្ធ

ផល ដែលបានមកពីការចុះប្រមូលព័ត៌មានតាមរយៈកម្រងសំណួរពីសិស្សានុសិស្សចំនួន១២ អនុវិទ្យាល័យដែលមានសិស្សសរុប៥០០នាក់ដែលបានចូលរួមបំពេញកម្រងសំណួរ។

### ១. វិធីសាស្ត្រផ្ទាល់

ក្រាបទី១៨៖ ការបង្រៀនដោយការប្រើប្រាស់វិធីសាស្ត្រផ្ទាល់




តាមក្រាបខាងលើបានបង្ហាញថា សិស្ស៣៣.៧១% បានផ្តល់ចម្លើយថាគ្រូបានប្រើប្រាស់វិធីសាស្ត្រផ្ទាល់គ្រប់ពេលនៅពេលដែលគ្រូបង្រៀន សិស្ស៣៤.១១%ផ្តល់ចម្លើយថា គ្រូប្រើប្រាស់វិធីសាស្ត្រនេះញឹកញាប់ សិស្ស ២៥.៦១% ថាគ្រូកម្រប្រើប្រាស់វិធីសាស្ត្រនេះណាស់ និងសិស្ស ៦.៥៧% ថាគ្រូមិនដែលប្រើប្រាស់វិធីសាស្ត្រនេះសោះ។ ដូចនេះ តាមលទ្ធផលដែលបានបង្ហាញខាងលើសិស្សបានផ្តល់ចម្លើយថា គ្រូបានប្រើប្រាស់វិធីសាស្តផ្ទាល់នេះច្រើនក្នុងពេលបង្រៀនសិស្ស។

## ២. វិធីសាស្ត្របកប្រែ

ក្រាបទី១៩៖ វិធីសាស្ត្របកប្រែ




តាមក្រាបខាងលើបានបង្ហាញថា សិស្សចំនួន៤៩.៦១% ថាគ្រូប្រើប្រាស់វិធីសាស្ត្របកប្រែគ្រប់ពេលវេលានៅពេលបង្រៀនសិស្ស ចំណែកឯសិស្ស៣០.៧៥%ថាគ្រូប្រើប្រាស់វិធីសាស្ត្រនេះញឹកញាប់នៅពេលបង្រៀន សិស្សចំនួន១៣.១១% ថាគ្រូកម្រប្រើប្រាស់វិធីសាស្ត្រនេះណាស់ និងសិស្សចំនួន៦.៥៤% ថាគ្រូមិនដែលប្រើប្រាស់វិធីសាស្ត្រនេះទាល់តែសោះ។ ដូចនេះតាមលទ្ធផលបានបង្ហាញថា គ្រូបានប្រើប្រាស់វិធីសាស្ត្របកប្រែច្រើនលើសលប់បំផុត។

## ៣. វិធីសាស្ត្របង្រៀនភាសាបែបចាក់សម្លេង

ក្រាបទី២០៖ វិធីសាស្ត្របង្រៀនភាសាបែបចាក់សម្លេង



តាមក្រាបខាងលើបានបង្ហាញថា សិស្សចំនួន៤.១១%ថាគ្រូប្រើប្រាស់វិធីសាស្ត្រ The Audio Lingual Methods គ្រប់ពេលនៅពេលបង្រៀន ចំណែកឯសិស្សចំនួន៥.៥០% ថាគ្រូបានប្រើប្រាស់វិធីសាស្ត្រនេះញឹកញាប់នៅពេលបង្រៀន សិស្សចំនួន២៨.១៨% ថាគ្រូកម្រប្រើប្រាស់វិធីសាស្ត្រនេះណាស់ និងគ្រូចំនួន៦២.២១% មិនដែលប្រើប្រាស់វិធីសាស្ត្រនេះទាល់តែសោះ។ ដូចនេះតាមលទ្ធផលខាងលើបង្ហាញថា គ្រូភាគច្រើនបំផុតមិនប្រើប្រាស់វិធីសាស្ត្រនេះនៅក្នុងការបង្រៀនរបស់ខ្លួនទេ។

### ៤. វិធីសាស្ត្របង្រៀនភាសាបែបចាក់ភ្លេង

ក្រាបទី២១៖ វិធីសាស្ត្របង្រៀនភាសាបែបចាក់ភ្លេង




តាមក្រាបខាងលើបានបង្ហាញថា សិស្ស៣.៧៩%បានផ្តល់ចម្លើយថាគ្រូបានប្រើប្រាស់វិធីសាស្ត្រ Suggestopedia គ្រប់ពេលដែលបង្រៀន ចំណែកឯសិស្ស៥.៣៩%ថាគ្រូប្រើប្រាស់វិធីសាស្ត្រនេះញឹកញាប់ គ្រូ២៦.១៨% កម្រប្រើវិធីសាស្ត្រនេះណាស់ និងគ្រូ៦៤.៦៤% មិន

ដែលប្រើប្រាស់វិធីសាស្ត្រនេះទាល់តែសោះ។ ដូចនេះ តាមលទ្ធផលខាងលើបានបង្ហាញថាគ្រូភាគច្រើនមិនបានប្រើប្រាស់វិធីសាស្ត្រនេះទេនៅពេលដែលបង្រៀនសិស្ស។

### ៥. វិធីសាស្ត្របង្រៀនភាសាឱ្យរាងកាយទទួល

ក្រាបទី២២៖ វិធីសាស្ត្របង្រៀនភាសាឱ្យរាងកាយទទួល




តាមក្រាបខាងលើបានបង្ហាញថា ក្នុងចំណោមសិស្ស៤០០នាក់ដែលបានចូលរួមផ្តល់ចម្លើយមានសិស្ស៤.២៥%ថាគ្រូបានប្រើប្រាស់វិធីសាស្ត្រនេះគ្រប់ពេលនៅពេលដែលបង្រៀនសិស្ស ចំណែកឯសិស្ស៧.៥៤%ថាគ្រូប្រើប្រាស់វិធីសាស្ត្រនេះញឹកញាប់ សិស្ស២៨.១៤%ទៀតថាគ្រូកម្រប្រើប្រាស់វិធីសាស្ត្រនេះណាស់ និងសិស្ស៦០.០៧%ទៀតថាគ្រូមិនដែលប្រើប្រាស់វិធីសាស្ត្រនេះសោះ។ ដូចនេះ ក្នុងពេលបង្រៀនសិស្សគ្រូភាគច្រើនមិនបានប្រើប្រាស់វិធីសាស្ត្រនេះទេក្នុងពេលដែលបង្រៀនសិស្ស។

## ៦. ការបង្រៀនភាសាតាមបែបទំនាក់ទំនង

ក្រាបទី២៣៖ វិធីសាស្ត្របង្រៀនភាសាតាមបែបទំនាក់ទំនង




តាមក្រាបខាងលើបានបង្ហាញថា សិស្ស៤.៧១%ថាគ្រូប្រើប្រាស់វិធីសាស្ត្របង្រៀនភាសាតាមបែបទំនាក់ទំនង ចំណែកឯសិស្ស៧.៧៩%ទៀតថាគ្រូប្រើប្រាស់វិធីសាស្ត្រនេះញឹកញាប់ សិស្ស២៧.៥០%ទៀតថាគ្រូកម្រប្រើប្រាស់វិធីសាស្ត្រនេះណាស់ និងសិស្ស៦០%ទៀតថាគ្រូមិនដែលប្រើប្រាស់វិធីសាស្ត្រនេះទាល់តែសោះ។ ដូចនេះតាមលទ្ធផលខាងលើបានបង្ហាញថា គ្រូមិនដែលប្រើប្រាស់វីធីសាស្ត្របង្រៀនភាសាតាមបែបទំនាក់ទំនងនេះទេនៅពេលបង្រៀនសិស្ស។

## ៧. ការបង្រៀនភាសាតាមបែបសហគមន៍

ក្រាបទី២៤៖ វិធីសាស្ត្របង្រៀនភាសាតាមបែបសហគមន៍




តាមក្រាបខាងលើបានបង្ហាញថា សិស្ស៣.៣៦%ថាគ្រូប្រើប្រាស់វិធីសាស្ត្របង្រៀនភាសាតាមបែបសហគមន៍ ចំណែកឯសិស្ស៧%ថាគ្រូប្រើប្រាស់វិធីសាស្ត្រនេះញឹកញាប់ សិស្ស២៦.៨៦%ថាគ្រូកម្រប្រើប្រាស់វិធីសាស្ត្រនេះណាស់ និងសិស្ស៦២.៧៩% ថាគ្រូមិនដែលប្រើប្រាស់វិធីសាស្ត្រនេះទាល់តែសោះ។ ដូចនេះតាមលទ្ធផលខាងលើបានបង្ហាញថា គ្រូមិនបានប្រើប្រាស់វិធីសាស្ត្របង្រៀនភាសាតាមបែបសហគមន៍ទេនៅពេលបង្រៀនសិស្ស។

## ៨. ការបង្រៀនភាសាដោយផ្អែកលើកិច្ចការ

ក្រាបទី២៥៖ ការបង្រៀនភាសាដោយផ្អែកលើកិច្ចការ




តាមក្រាបខាងលើបានបង្ហាញថា សិស្ស៥.១៨%បានផ្តល់ចម្លើយថាគ្រូប្រើប្រាស់វិធីសាស្រ្តបង្រៀនតាមបែបដាក់កិច្ចការគ្រប់ពេលបង្រៀនសិស្ស ចំណែកឯសិស្ស ៧.៨២%ប្រើប្រាស់វិធីសាស្រ្តនេះញឹកញាប់ ឯសិស្ស២៤.៥០%ថាគ្រូកម្រប្រើប្រាស់វិធីសាស្រ្តនេះណាស់ និងសិស្សចំនួន៦២.៥០%ថាគ្រូមិនដែលបានប្រើប្រាស់វិធីសាស្រ្តនេះទាល់តែសោះ។ ដូចនេះតាមលទ្ធផលខាងលើបានបង្ហាញថាគ្រូមិនបានប្រើប្រាស់វិធីសាស្រ្តនេះទាល់តែសោះ។

### ៤.១.៣. ប្រសិទ្ធភាពនៃការបង្រៀនរបស់គ្រូ

ដើម្បីឱ្យកាន់តែជាក់លាក់និងពិតប្រាកដថា ការប្រើប្រាស់វិធីសាស្រ្តបង្រៀនរបស់លោកគ្រូអ្នកគ្រូទទួលបានលទ្ធផលបែបណានោះ អ្នកសិក្សាស្រាវជ្រាវនឹងពិនិត្យមើលទៅលើលទ្ធផលសិក្សារបស់សិស្សដែលលោកគ្រូអ្នកគ្រូកំពុងតែបង្រៀននោះ។

## ១. កម្រិតនៃការចូលរួមរបស់សិស្សក្នុងសកម្មភាពបង្រៀន

ក្រាបទី២៦៖ កម្រិតនៃការចូលរួមក្នុងសកម្មភាពរៀន




តាមក្រាបខាងលើបានបង្ហាញថា គ្រូ១៨.៧៥%ថាសិស្សបានចូលរួម ក្នុងសកម្មភាពរៀនខ្លាំង ចំណែកឯសិស្ស៥៦.២៥%ទៀតថាសិស្សបានចូលរួមក្នុងសកម្មភាពជាមធ្យម គ្រូ៦.២៥%ទៀតថាសិស្សបានចូលរួមក្នុងសកម្មភាពរៀនតិចតួចតែប៉ុណ្ណោះ និងគ្រូ១៨.៧៥%ថាសិស្សមិនចូលរួមក្នុងសកម្មភាពរៀនទាល់តែសោះ។ ដូចនេះតាមលទ្ធផលខាងលើបានបង្ហាញថា ក្នុងពេលកំពុងបង្រៀនសិស្សបានចូលរួមក្នុងសកម្មភាពរៀនមធ្យម។

## ២. កម្រិតខ្លឹមសារមេរៀនដែលសិស្សទទួលបាន

ក្រាបទី២៧៖កម្រិតខ្លឹមសារមេរៀនដែលសិស្សទទួលបាន



តាមក្រាបខាងលើបានបង្ហាញថា គ្រូ២៥%ថាសិស្សទទួលបានខ្លឹមសារមេរៀនច្រើនពីការបង្រៀន ចំណែកឯគ្រូ៤៣.៧៥%ទៀតថាសិស្សទទួលបានខ្លឹមសារមេរៀនធម្មតា ឬជាមធ្យម គ្រូ៩.៣៨% ថាសិស្សទទួលបានខ្លឹមសារមេរៀនតិចតួច និងគ្រូ២១.៨៨%ថាសិស្សមិនទទួលបានអ្វីទាល់តែសោះពីការបង្រៀនភាសាអង់គ្លេសនេះ។ ដូចនេះតាមលទ្ធផលខាងលើបានបង្ហាញថាសិស្សទទួលបានខ្លឹមសារមេរៀនពីការបង្រៀនបានមធ្យម។

### ៣. ចំណាប់អារម្មណ៍របស់សិស្សចំពោះការបង្រៀន

ក្រាបទី២៨៖ ចំណាប់អារម្មណ៍របស់សិស្សចំពោះការបង្រៀន




តាមក្រាបខាងលើបានបង្ហាញថា គ្រូ៤៣.៧៥%ថាសិស្សចាប់អាររម្មណ៍ចំពោះការបង្រៀនភាសាអង់គ្លេសនេះខ្លាំងណាស់ ចំណែកឯគ្រូ៣៧.៥%ថាសិស្សចាប់អារម្មណ៍ធម្មតា គ្រូ៩.៣៨%ទៀតថាសិស្សចាប់អារម្មណ៍តិចតួច និងគ្រូ៩.៣៨%ថាសិស្សមិនចាប់អារម្មណ៍ចំពោះការបង្រៀននេះទេ។ ដូចនេះតាមលទ្ធផលខាងលើបានបង្ហាញថាសិស្សដែលចាប់អារម្មណ៍ចំពោះការបង្រៀនរបស់គ្រូនៅតែមានចំនួនច្រើន។

## ៤. សកម្មភាពរៀនដែលផ្តល់ឱ្យសិស្ស

ក្រាបទី២៩៖ការរៀបចំសកម្មភាពរៀន




តាមក្រាបខាងលើបានបង្ហាញថា គ្រូ៥៣.១៣%បានរៀបចំសកម្មភាពរៀនមានលក្ខណៈជាក្រុមដើម្បីឱ្យសិស្សពិភាក្សាគ្នា ចំណែកឯគ្រូ២៥%ទៀតបានរៀបចំសកម្មភាពជាគូរ ឯ១២.៥%បានរៀបចំសកម្មភាពជាបុគ្គល និងគ្រូ៩.៣៨%មិនបានរៀបចំសកម្មភាពអ្វីទាំងអស់សម្រាប់ឱ្យសិស្សរៀននោះទេ។ ដូចនេះតាមលទ្ធផលខាងលើបង្ហាញថាគ្រូភាគច្រើនបានរៀបចំឱ្យសិស្សធ្វើការងារជាក្រុម ឬអាចហៅម្យ៉ាងទៀតថាសិស្សមជ្ឈមណ្ឌល។

## ៥. លទ្ធផលសិក្សារបស់សិស្ស

ក្រាបទី៣០៖លទ្ធផលសិក្សារបស់សិស្ស



តាមក្រាបខាងលើបានបង្ហាញថា គ្រូ៣.១៣%ថាសិស្សទទួលបានលទ្ធផលសិក្សាល្អណាស់ ចំណែកឯគ្រូ៣៧.៥%ទៀតថាសិស្សទទួលបានលទ្ធផលសិក្សាល្អបង្គួរ ឯគ្រូ៤០.៦៣% ទៀថាសិស្សទទួលបានលទ្ធផលសិក្សាមធ្យម និងគ្រូ១៨.៧៥%ថាសិស្សទទួលបានលទ្ធផលសិក្សាខ្សោយ។ ដូចនេះតាមលទ្ធផលខាងលើបានបង្ហាញថា សិស្សដែលរៀនខ្សោយមានចំនួនត្រឹមតែ ១៨.៧៥% ប៉ុណ្ណោះ។

## ៦. ការពេញចិត្តរបស់គ្រូចំពោះការបង្រៀន

ក្រាបទី៣១៖ កម្រិតនៃការពេញចិត្តរបស់គ្រូចំពោះការបង្រៀន




តាមក្រាបខាងលើបានបង្ហាញថា គ្រូ៤៣.៧៥%មានសេចក្ដីពេញចិត្តចំពោះការបង្រៀនភាសាអង់គ្លេសនេះណាស់ ចំណែកឯគ្រូ៣៧.៥%បានពេញចិត្តធម្មតា ឯគ្រូ៩.៣៨%ពេញចិត្តតិចតួច និងគ្រូ៩.៣៨% មិនពេញចិត្តចំពោះការបង្រៀនភាសាអង់គ្លេសនេះទេ។ ដូចនេះតាមលទ្ធផលខាងលើបានបង្ហាញថា គ្រូមានសេចក្ដីពេញចិត្តចំពោះការបង្រៀនភាសាអង់គ្លេសនេះមានកម្រិតខ្ពស់។

### ៤.១.៤. ប្រសិទ្ធភាពនៃការបង្រៀនរបស់គ្រូ(សិស្ស)

លទ្ធផលសិក្សាដែលសិស្សទទួលបាន ពីការបង្រៀនរបស់គ្រូដែលគ្រូប្រើប្រាស់វិធីសាស្រ្តញឹកញាប់ជាងគេនោះ អ្នកសិក្សាស្រាវជ្រាវនឹងពិនិត្យមើលម្លើយដែលសិស្សបានផ្តល់ឱ្យនៅក្នុងការបំពេញកម្រងសំណួរនោះ។

#### ១. កម្រិតនៃការចូលរួមរបស់សិស្សក្នុងសកម្មភាពរៀន

ក្រាបទី៣២៖ ការចូលរួមក្នុងសកម្មភាពរៀនរបស់សិស្ស




តាមក្រាបខាងលើបានបង្ហាញថា សិស្ស១៥%បានចូលរួមក្នុងសកម្មភាពរៀនភាសាអង់គ្លេសនេះមានលក្ខណៈសកម្មខ្លាំង ចំណែកឯសិស្ស៧១%ទៀតបានចូលរួមក្នុងសកម្មភាពរៀនធម្មតា ឯសិស្ស១៣.៥%បានចូលរួមក្នុងសកម្មភាពរៀននេះតិចតួច និងសិស្ស០.៥%មិនដែលចូលរួមក្នុងសកម្មភាពរៀនភាសាអង់គ្លេសនេះសោះ។ ដូចនេះតាមលទ្ធផលខាងលើបានបង្ហាញថាសិស្សបានចូលរួមក្នុងសកម្មភាពរៀនភាសាអង់គ្លេសនេះមិនសូវសកម្មណាស់ណាទេ។

#### ២. កម្រិតខ្លឹមសារមេរៀនដែលសិស្សទទួលបាន

ក្រាបទី៣៣៖ កម្រិតខ្លឹមសារមេរៀនដែលសិស្សទទួលបាន




តាមក្រាបខាងលើបានបង្ហាញថា សិស្ស៣៦.៧៥%ទទួលបានខ្លឹមសារមេរៀនច្រើនពីការរៀនភាសាអង់គ្លេសនេះ ចំណែកឯសិស្ស៤៤.៥%ទៀតទទួលបានខ្លឹមសារមេរៀនធម្មតា ឯសិស្ស១៨.៥%ទទួលបានខ្លឹមសារមេរៀនតិចតួច និងសិស្ស០.២៥%មិនបានទទួលខ្លឹមសារមេរៀនអ្វីសោះ។ ដូចនេះតាមលទ្ធផលខាងលើបានបង្ហាញថា វិធីសាស្រ្តដែលគ្រូប្រើក្នុងការបង្រៀនសិស្សជារៀងរាល់ថ្ងៃនោះ សិស្សទទួលបានខ្លឹមសារមេរៀនពីការរៀនភាសាអង់គ្លេសនេះមានចំនួនច្រើន។

### ៣. ចំណាប់អារម្មណ៍របស់សិស្សចំពោះការរៀន

ក្រាបទី៣៩៖ចំណាប់អារម្មណ៍របស់សិស្ស



តាមក្រាបខាងលើបានបង្ហាញថា សិស្ស៣៣.៥% មានចំណាប់អារម្មណ៍ខ្លាំងចំពោះការរៀនមេរៀនភាសាអង់គ្លេសនេះណាស់ ចំណែកឯសិស្ស៤៩.៧៥%មានចំណាប់អារម្មណ៍ធម្មតា សិស្ស១៥.៧៥% ចាប់អារម្មណ៍តិចតួច និងសិស្ស១%ទៀតមិនចាប់អារម្មណ៍សោះចំពោះការរៀនមេរៀនភាសាអង់គ្លេសនេះ។ ដូចនេះ តាមលទ្ធផលខាងលើបានបង្ហាញថា សិស្សភាគច្រើនចាប់អារម្មណ៍ចំពោះការរៀនមេរៀនភាសាអង់គ្លេសនេះ។

### ៤. សកម្មភាពរៀនដែលសិស្សបានធ្វើ

ក្រាបទី៣៥៖សកម្មភាពសិស្សរៀនក្នុងថ្នាក់




តាមក្រាបខាងលើបានបង្ហាញថា សិស្ស៤៥.៧៥%បានផ្តល់ចម្លើយថាគ្រូបានរៀបចំសកម្មភាពរៀនជាលក្ខណៈក្រុមពិភាក្សា ចំណែកឯសិស្ស២៦.៥%ទៀតថាគ្រូបានរៀបចំសកម្មភាពរៀនធ្វើការជាគូរ ឯសិស្ស២៣.៧៥%ថាគ្រូរៀបចំសកម្មភាពរៀនជាលក្ខណៈបុគ្គល

និងសិស្សចំនួន៤%ថាគ្រូមិនបានរៀបចំសកម្មភាពរៀនអ្វីសោះ។ ដូចនេះតាមលទ្ធផលខាងលើបានបង្ហាញថាគ្រូបានរៀបចំឱ្យសិស្សធ្វើសកម្មភាពពិភាក្សាក្រុមនៅក្នុងការបង្រៀន។

### ៥. លទ្ធផលសិក្សារបស់សិស្ស

ក្រាបទី៣៦៖លទ្ធផលសិក្សារបស់សិស្ស




តាមក្រាបខាងលើបានបង្ហាញថា សិស្សចំនួន៦.២៥%ទទួលបានលទ្ធផលល្អតាមរយៈការបង្រៀនរបស់គ្រូ ចំណែកឯសិស្ស៤០.៥%ទទួលបានលទ្ធផលល្អ សិស្សចំនួន៤៧.២៥%ទទួលបានលទ្ធផលមធ្យម និងសិស្សចំនួន៦%ទទួលបានលទ្ធផលខ្សោយ។ ដូចនេះ តាមលទ្ធផលខាងលើបានបង្ហាញថាគ្រូដែលបានប្រើប្រាស់វិធីសាស្ត្រផ្ទាល់ និងវិធីសាស្ត្របកប្រែ ធ្វើឱ្យលទ្ធផលសិក្សារបស់សិស្សជាប់រហូតដល់៩៦%។

### ៦. ប្រសិទ្ធភាពនៃវិធីសាស្ត្រផ្ទាល់ និង វិធីសាស្ត្របកប្រែ

ក្រាបទី៣៧៖ ការប្រៀបធៀបប្រសិទ្ធភាពនៃវិធីសាស្ត្រផ្ទាល់ និងវិធីសាស្ត្របកប្រែ




តាមក្រាបខាងលើបានបង្ហាញថា សម្រាប់វិធីសាស្ត្រផ្ទាល់សិស្ស២% មាននិទ្ទេសខ្សោយ សិស្ស១៤.៥% មាននិទ្ទេសមធ្យម សិស្ស១៣%មាននិទ្ទេសល្អបង្គួរ និងសិស្ស២.៥% មាននិទ្ទេសល្អណាស់។ ចំណែកឯវិធីសាស្ត្របកប្រែវិញ សិស្ស៤% មាននិទ្ទេសខ្សោយ សិស្ស៣២.៥% មាននិទ្ទេសមធ្យម សិស្ស២៧.២៥% មាននិទ្ទេសល្អបង្គួរ និងសិស្ស៤.២៥% មាននិទ្ទេសល្អណាស់។ ដូចនេះ វិធីសាស្ត្រផ្ទាល់មានសិស្សជាប់មធ្យមភាគមានត្រឹមតែ៣០%តែប៉ុណ្ណោះ ចំណែកឯវិធីសាស្ត្របកប្រែមានសិស្សជាប់មធ្យមភាគរហូតដល់ទៅ៦៤%។

## ៧. ការពេញចិត្តរបស់សិស្សចំពោះការរៀន

ក្រាបទី៣៨៖កម្រិតនៃការពេញចិត្តរបស់សិស្ស



តាមក្រាបខាងលើបានបង្ហាញថា ក្នុងចំណោមសិស្ស៥០០នាក់មានសិស្ស៣៩.៥០% ចូលចិត្តរៀនភាសាអង់គ្លេស ចំណែកឯសិស្ស៤៦.៧៥%មានអារម្មណ៍ធម្មតាចំពោះការបង្រៀនភាសាអង់គ្លេស សិស្ស១៣.២៥%ពេញចិត្តតិចតួចចំពោះការបង្រៀនភាសាអង់គ្លេស និងសិស្ស០.៥%មិនចូលចិត្តរៀនភាសាអង់គ្លេសទាល់តែសោះ។ ដូចនេះ តាមលទ្ធផលបានបង្ហាញថាសិស្សចំនួនលើ៥០%នៅតែចូលចិត្តការរៀនភាសាអង់គ្លេសណាស់។

## ៤.២. ការពិភាក្សា

### ៤.២.១. ឯកទេសរបស់គ្រូបង្រៀន

ចំពោះគ្រូបង្រៀន ដែលកំពុងបង្រៀនភាសាអង់គ្លេសនៅមធ្យមសិក្សាបឋមភូមិក្នុងចំណោមគ្រូ៣២នាក់ មានគ្រូ២៨នាក់ស្មើនឹង៨៧.៥%ដែលមានឯកទេសភាសាអង់គ្លេស ចំណែកឯគ្រូ៤នាក់ស្មើនឹង១២.៥%ដែលបង្រៀនខុសឯកទេស។

### ៤.២.២. ភាពញឹកញាប់នៃការប្រើប្រាស់វិធីសាស្ត្របង្រៀន

#### ១. វិធីសាស្ត្រផ្ទាល់

ចំពោះគ្រូ៣២នាក់មានគ្រូ៦៥.៦២% ដែលបានប្រើប្រាស់វិធីសាស្ត្រផ្ទាល់ញឹកញាប់ ហើយមានតែគ្រូ៣៤.៣៨% កម្រប្រើប្រាស់ ឬមិនប្រើប្រាស់វិធីសាស្ត្រនេះទាល់តែសោះ។

ចំពោះសិស្ស៥០០នាក់មានសិស្ស៦៧.៨២% ថាគ្រូប្រើប្រាស់វិធីសាស្ត្រផ្ទាល់ញឹកញាប់ ហើយសិស្ស៣២.១៨%ថាគ្រូកម្រប្រើប្រាស់ ឬមិនប្រើប្រាស់វិធីសាស្ត្រនេះទាល់តែសោះ។

ដូចនេះតាមលទ្ធផលដែលផ្តល់ដោយគ្រូ និងលទ្ធផលដែលបានផ្តល់ដោយសិស្សបានបង្ហាញថា គ្រូ៦៦.៧២%បានប្រើប្រាស់វិធីសាស្ត្រផ្ទាល់ញឹកញាប់។

### ២. វិធីសាស្ត្របកប្រែ

